# បញ្ជីចំណុចដែលត្រូវធ្វើ ដើម្បីបញ្ចប់អំណាចផ្តាច់ការ

## The Checklist for Ending Tyranny

**Peter Ackerman and Hardy Merriman**

From the book: ‘Is Authoritarianism Staging a Comeback?’
Editors: Matthew Burrows and Maria J. Stephan
The Atlantic Council, Washington D.C. — 2015
Translation: October 2020

# បញ្ជីចំណុចដែលត្រូវធ្វើ ដើម្បីបញ្ចប់អំណាចផ្តាច់ការ

## ដោយ ភីទ័រ អែកឺមែន និងហាតឌី មេរីមែន

បច្ចុប្បន្ននេះ ជម្លោះដែលគ្រោះថ្នាក់ជាទីបំផុតនៅក្នុងពិភពលោក មិនមែនរវាងរដ្ឋនិងរដ្ឋនោះទេ ប៉ុន្តែគឺនៅក្នុងរដ្ឋទៅវិញទេ នោះគឺការដាក់ឱ្យជនផ្តាច់ការនៅតទល់នឹងប្រជាពលរដ្ឋដែលគេគាបសង្កត់។ មានការជឿជាក់ដ៏ទូលំទូលាយថា ប្រជាពលរដ្ឋដែលត្រូវបានគាបសង្កត់ទាំងនេះ មានជម្រើសពីរ ៖ ព្រមទទួលយកអំណាចផ្តាច់ការដោយសង្ឃឹមថាស្ថានភាពនឹងកាន់តែធូរស្រាលជាងមុន ឬក៏រៀបចំការបះបោរប្រដាប់អាវុធដើម្បីទាមទារសេរីភាព។ ទស្សនៈ ដែលមានកម្រិតនេះ ត្រូវបានបដិសេធដោយការពិតដែលថា យុទ្ធនាការតស៊ូដោយពលរដ្ឋ (ពេលខ្លះសំដៅថា ចលនា «អំណាចប្រជាពលរដ្ឋ» ឬជម្លោះអហិង្សា) បានកើតឡើងជាញឹកញាប់ជាងអ្វីដែលមនុស្សម្នាទូទៅបានដឹង។ ចាប់ផ្តើមក្នុងឆ្នាំ ១៩០០ មានយុទ្ធនាការសំខាន់នៃការតស៊ូដោយពលរដ្ឋជាមធ្យមមួយ ប្រឆាំងនឹងមេដឹកនាំដែលកំពុងកាន់តំណែងក្នុងមួយឆ្នាំ។[1] ចលនាដឹកនាំដោយពលរដ្ឋទាំងអស់នេះ កាន់តែអាចកំណត់លទ្ធផលនៃជម្លោះភូមិសាស្ត្រនយោបាយដ៏សំខាន់ និងអន្តរកាលនៃលទ្ធិប្រជាធិបតេយ្យ តាំងពីឆ្នាំ១៩៧២។[2] ប៉ុន្តែអ្នកបង្កើតគោលនយោបាយ បញ្ញវន្ត អ្នកសារព័ត៌មាន និងអ្នកសង្កេតការណ៍ដែលចាប់អារម្មណ៍ជាច្រើននាក់ តែងតែមើលស្រាលនូវសមត្ថភាពរបស់ប្រជាពលរដ្ឋសាមញ្ញក្នុងការធ្វើឱ្យអំណាចផ្តាច់ការរង្គោះរង្គើ និងទទួលបានសិទ្ធិរបស់ពួកគេដោយមិនប្រើហិង្សា។

[1] ផ្អែកលើការស្រាវជ្រាវដោយ អេរីកា ឈើណូវិត និងម៉ារៀ ស្ទេហ្វិន ដែលបានរកឃើញយុទ្ធនាការតស៊ូដោយពលរដ្ឋចំនួន ១០៥ ដែលទាមទារការផ្លាស់ប្តូររដ្ឋាភិបាលក្នុងប្រទេស និងតំបន់នៅជុំវិញពិភពលោករវាងឆ្នាំ ១៩០០ -២០០៦។

ឈើណូវិត, អេរីកា និង ម៉ារៀ ស្ទេហ្វេន, ២០១១ «ហេតុអ្វីបានជាការតស៊ូដោយពលរដ្ឋមានប្រសិទ្ធភាព៖ តក្កវិទ្យាយុទ្ធសាស្ត្រនៃជម្លោះអហិង្សា», ញូវយ៉កសារព័ត៌មាននៃសាកលវិទ្យាល័យកូឡុំប៊ី ទំព័រទី៦

ណាវកូ ១.១ ទិន្នន័យអាចរកបាន៖ https://www.du.edu/korbel/sie/research/chenow_navco_data.html

[2] ផ្អែកលើ អន្តរកាលទៅកាន់លទ្ធិប្រជាធិបតេយ្យចំនួន ៦៧ ដែលត្រូវបានវិភាគក្នុងអំឡុង ១៩៧២ ដល់ ២០០៥ ក្នុងការស្រាវជ្រាវ «តើសេរីភាពអាចឈ្នះដោយរបៀបណា ៖ ពីការតស៊ូដោយពលរដ្ឋទៅលទ្ធិប្រជាធិបតេយ្យជាប់លាប់»។ អ្នកនិពន្ធបានរកឃើញថា ៖

«កម្លាំងនៃការតស៊ូដោយពលរដ្ឋ គឺជាកត្តាសំខាន់ក្នុងការដឹកនាំអន្តរកាលចំនួន ៥០ ក្នុងចំណោម ៦៧ ឬក៏ ៧០ភាគរយនៃប្រទេសដែលអន្តរកាលចាប់ផ្តើមដោយប្រព័ន្ធផ្តាច់ការដួលរលំ និង/ឬ រដ្ឋថ្មីកកើតឡើងពីការបែកបាក់នៃរដ្ឋជាច្រើន។ ក្នុងចំណោមប្រទេសចំនួន ៥០ ដែលការតស៊ូដោយពលរដ្ឋជា យុទ្ធសាស្ត្រសំខាន់ (ដូចជា ទាំងប្រទេសដែលអន្តរកាលត្រូវបាននាំដោយកម្លាំងពលរដ្ឋ ឬប្រទេសដែលមានការលាយឡំនៃអន្តរកាល ដែលចូលរួមយ៉ាងសំខាន់ពីកម្លាំងពលរដ្ឋ និងអ្នកកាន់អំណាច) ពុំមានប្រទេសណាមួយដែលជាប្រទេសសេរី មានប្រទេសចំនួន ២៥ ដែលជាប្រទេសសេរីដោយផ្នែក និងប្រទេសចំនួន ២៥ ជាប្រទេសដែលមិនសេរី។ បច្ចុប្បន្ន (ក្នុងឆ្នាំ២០០៥) ជាច្រើនឆ្នាំបន្ទាប់ពីអន្តរកាលនៃប្រទេសចំនួន ៣២ ក្នុងចំណោមប្រទេសទាំងនេះ ជាប្រទេសសេរីចំនួន ១៤ ជាប្រទេសដែលសេរីដោយផ្នែក និងមានត្រឹមតែប្រទេស ៤ ទេ ដែលមិនសេរី។»

អែកឺមែន ភីទ័រ និង អែនឌ្រៀន ការ៉ាតនិកគី ឆ្នាំ២០០៥ «តើសេរីភាពអាចឈ្នះដោយរបៀបណា ៖ ពីការតស៊ូដោយពលរដ្ឋទៅលទ្ធិប្រជាធិបតេយ្យជាប់លាប់» វ៉ាស៊ីងតោន ឌីស៊ី៖ ហ្វ្រីដុម ហៅស៍ ទំព័រ ៦ ដល់ ៧។

**ជំពូកនេះមាននៅក្នុង ៖ ម៉ាធីវ ប៊ូរ៉ូយ និង ម៉ារៀ ជេ. ស្ទេហ្វិន, «តើអំណាចផ្តាច់ការនិយមកំពុងតែរៀបចំផែនការត្រលប់មកវិញ?» វ៉ាស៊ីងតោន ឌីស៊ី ក្រុមប្រឹក្សាអាត្លង់ទិច, ឆ្នាំ២០១៥។**

## ការវិភាគនៃចំណុចកំបាំង

ការបះបោរនៅទុយនីស៊ី និងអេហ្ស៊ីបក្នុងឆ្នាំ២០១១ និងថ្មីៗនៅអ៊ុយក្រែន ក្នុងឆ្នាំ២០១៤ ជាឧទាហរណ៍នៃការតស៊ូដោយពលរដ្ឋកម្រិតមូលដ្ឋាន អាចធ្វើឱ្យមនុស្សជាច្រើនភ្ញាក់ផ្អើលដោយសារតែអំណាច និងសក្ដានុពលដែលអាចធ្វើឱ្យមានការផ្លាស់ប្ដូរនៃការតស៊ូទាំងនេះ។ ពុំមាននរណាម្នាក់អាចដឹងថានឹងមានការបះបោរទាំងអស់នេះនោះទេ ប៉ុន្តែចំណុចនេះហើយដែលធ្វើឱ្យការបះបោរនេះមានលក្ខណៈខុសប្លែក។ ហើយប្រសិនបើមាន ក៏មានមនុស្សតិចតួចណាស់ដែរ ដែលមើលឃើញថា «បដិវត្តន៍ពណ៌» នឹងកើតឡើងនៅស៊ែប៊ី (២០០០) ហ្សកហ្ស៊ី (២០០៣) និងអ៊ុយក្រែន (២០០៤)។ ក្នុងទស្សវត្សរ៍មុនៗ ពុំមាននរណារំពឹងទុកថាការតស៊ូដោយអហិង្សាដែលត្រូវបានរៀបចំ អាចដើរតួនាទីក្នុងការធ្វើសេចក្ដីសម្រេចដ៏សំខាន់ក្នុងការផ្ដួលរំលំជនផ្ដាច់ការហ្វីលីពីន ហ្វឺឌីណង់ ម៉ាកូស (១៩៨៦) ជនផ្ដាច់ការស៊ីលី អាហ្គុស្តូ ភីណូឆេត (១៩៨៨) និងរបបគ្រប់គ្រងសូវៀតនៅប៉ូឡូញ (១៩៨៩) ឬក៏របបរើសអើងពូជសាសន៍នៅអាហ្វ្រិកខាងត្បូង (១៩៩២) នោះដែរ។

អ្នកជំនាញថ្នាក់តំបន់ និងអន្តរជាតិ ពិបាកនឹងពន្យល់ពីជម្លោះអហិង្សាទាំងអស់នេះ និងចលនាដទៃទៀត ពួកគេជាញឹកញាប់សន្និដ្ឋានថាការតស៊ូដោយពលរដ្ឋដែលជោគជ័យ គឺជាភាពមិនប្រក្រតីក្នុងប្រវត្តិសាស្ត្រដោយផ្អែកលើកាលៈទេសៈមួយចំនួនដែលខុសប្លែកគេ នៅប្រទេសមួយនោះ ក្នុងខណៈនោះដែរ។ ដោយសារតែកម្លាំងរបស់ចលនាត្រូវបានមើលឃើញថាផ្អែកលើករណីផ្សេងៗគ្នា ជាក់លាក់ ពួកគេមិនត្រូវបានចាត់ទុកជាភស្តុតាងនៃយុទ្ធសាស្ត្រជាទូទៅ ដែលប្រជាពលរដ្ឋអាចប្រើអំណាចរបស់ខ្លួន ប្រឆាំងនឹងជនគាបសង្កត់ផ្សេងៗគ្នាជាច្រើននោះទេ។ ប៉ុន្តែ ជនផ្ដាច់ការជុំវិញពិភពលោកមិនបានទទួលរងទុក្ខពី ចំណុចកំបាំងនេះទេ។ ពួកគេចាប់ផ្ដើមដឹងថាចលនាអំណាចប្រជាពលរដ្ឋ គឺជាការគំរាមកំហែងធំបំផុតសម្រាប់ការដឹកនាំជាបន្តបន្ទាប់របស់ពួកគេ។

ដោយហេតុការណ៍នៃជម្លោះអហិង្សាកើតមានកាន់តែច្រើនឡើងៗ ក្នុងទស្សវត្សរ៍ចុងក្រោយនេះ វាពិតជាមានសារៈសំខាន់ខ្លាំងណាស់ សម្រាប់អ្នកគាំទ្រការផ្លាស់ប្ដូរបែបប្រជាធិបតេយ្យ ដើម្បីធ្វើបច្ចុប្បន្នភាពការយល់ដឹងរបស់ពួកគេ អំពីហេតុអ្វីបានជាចលនាអំណាចប្រជាពលរដ្ឋអាចទទួលជោគជ័យ។ ជម្លោះអហិង្សាអាចប្រើបានចំពោះករណីជាច្រើនផ្សេងៗគ្នា ដោយសារតែជម្លោះប្រភេទនេះ ទាញយកផលប្រយោជន៍ពីតថភាពមូលដ្ឋានចំនួនពីរ ៖ គឺថារបបផ្ដាច់ការពឹងផ្អែកទៅលើការគោរពទ្រង់ទ្រាយធំ ពីប្រជាពលរដ្ឋដែលគេអាចគ្រប់គ្រងដើម្បីរក្សាអំណាចរបស់ពួកគេ និងគឺថាមិនមែនមនុស្សគ្រប់គ្នានៅក្នុងរបបនេះសុទ្ធតែមានភក្ដីភាពស្មើៗគ្នានោះទេ។

ជំពូកនេះមាននៅក្នុង ៖ ម៉ាជីរ ប៊្រូយ និង ម៉ារៀ ជេ. ស្ទេហ្វិន, «តើអំណាចផ្ដាច់ការនិយមកំពុងតែរៀបចំផែនការត្រលប់មកវិញ?» វ៉ាស៊ីងតោន ឌីស៊ី ក្រុមប្រឹក្សាអាត្លង់ទិច, ឆ្នាំ២០១៥។

## តើការតស៊ូដោយពលរដ្ឋអាចមានប្រសិទ្ធភាពបានដោយរបៀបណា?

ផ្អែកលើតថភាពពីរ ពលរដ្ឋអ្នកតស៊ូកៀរគរប្រជាពលរដ្ឋឱ្យបោះបង់ការគោរពរបស់ពួកគេ (ចំពោះរដ្ឋ) ជាប្រព័ន្ធ និងដាក់គំនាបអហិង្សា តាមរយៈយុទ្ធវិធីដូចជា កូដកម្ម ពហិកា បាតុកម្មទ្រង់ទ្រាយធំ និងសកម្មភាពផ្សេងៗទៀត ដើម្បីធ្វើឱ្យរំខានដល់ប្រព័ន្ធគាបសង្កត់ និងទាមទារសិទ្ធិ សេរីភាព និងយុត្តិធម៌។ នៅពេលដែលការចូលរួមក្នុងការតស៊ូដោយពលរដ្ឋកាន់តែចម្រុះ និងកាន់តែកើនឡើង ការបង្ក្រាបមកលើអ្នកតស៊ូតែងតែមិនគ្រប់គ្រាន់ក្នុងការស្តារនូវភាពស្ងប់ស្ងាត់នោះទេ ផ្ទុយទៅវិញ អាចនឹងបង្កឱ្យមានផលអវិជ្ជមានបកមកវិញទៀតផង។

ខណៈដែលការរារាំងនៅតែបន្ត ភាពបែកបាក់ក៏ចាប់ផ្តើមកើតមាននៅក្នុងជួររដ្ឋាភិបាល និងស្ថាប័នដទៃទៀត (ដូចជា ប៉ូលីស ទាហាន សារព័ត៌មាន និងនយោបាយ ការិយាធិបតេយ្យ និងស្ថាប័នសេដ្ឋកិច្ច) ដែលសំខាន់ចំពោះរដ្ឋ។ ការបែកបាក់ទាំងនេះ តែងតែនាំទៅរកការចុះចូល ហើយនៅពេលដែលការចុះចូលមានកាន់តែច្រើនដូចទឹកបាក់ទំនប់ នោះសមត្ថភាពចម្បងដែលអំណាចផ្តាច់ការពឹងផ្អែកលើ សម្រាប់ការគ្រប់គ្រងរបស់គេ ដូចជាការគ្រប់គ្រងធនធានសម្ភារៈ ធនធានមនុស្ស ជំនាញ និងចំណេះដឹងរបស់មនុស្ស មជ្ឈដ្ឋានព័ត៌មាន និងសមត្ថភាពក្នុងការដាក់ទណ្ឌកម្ម ត្រូវបានបំផ្លាញ។ ពេលជនផ្តាច់ការពុំមានសង្វាក់នៃការត្រួតត្រាស្ថិតស្ថេរ ដែលពួកគេចេញបញ្ជាឱ្យធ្វើតាម នោះចុងក្រោយ ជនផ្តាច់ការនឹងលែងមានជម្រើស ហើយក៏ត្រូវបានបង្ខំឱ្យចុះចេញពីតំណែង ពីព្រោះតែការគាបសង្កត់អហិង្សាដែលមានស្ថិរភាព។ លទ្ធផលដែលទទួលបានជាញឹកញាប់នោះ គឺការផ្លាស់ប្តូរទាំងស្រុង។

## ជំនាញ ធៀបនឹង លក្ខខណ្ឌ

ស្របជាមួយនឹងការកើនឡើងនៃព្រឹត្តិការណ៍ និងឥទ្ធិពលនៃការតស៊ូដោយពលរដ្ឋ វាសំខាន់ណាស់ក្នុងការពិនិត្យមើលថាតើកត្តាអ្វីដែលកំណត់លទ្ធផលនៃការតស៊ូនេះ។ តើលក្ខខណ្ឌមុនពេលការចាប់ផ្តើមមានជម្លោះ អាចកំណត់ថាតើចលនា ឬក៏ជនផ្តាច់ការជាអ្នកឈ្នះ? ឬក៏ជ័យជំនះសម្រាប់ភាគីទាំងសងខាងត្រូវបានកំណត់ដោយជម្រើសយុទ្ធសាស្ត្រ និងភាពមានជំនាញដែលពួកគេប្រើដើម្បីបង្កជម្លោះ?

ផ្នែកដ៏សំខាន់មួយនៃបេសកកម្ម នៃមជ្ឈមណ្ឌលអន្តរជាតិស្តីពីជម្លោះអហិង្សា (ដែលយើងជាផ្នែកមួយ) គឺដើម្បីអះអាងថាជំនាញដែលមានតុល្យភាព មានសារៈសំខាន់ជាងលក្ខខណ្ឌក្នុងការកំណត់គន្លង និងលទ្ធផលនៃចលនា។ ចំណុចនេះ ជាធម្មតាតែងតែនាំមកនូវការរុញច្រានក្រោយដ៏សំខាន់ ជាពិសេសគឺផ្តោតលើ

ជំពូកនេះមាននៅក្នុង ៖ ម៉ាជីវ ប៊្រូយ និង ម៉ារៀ ជេ. ស្ទេហ្វិន, «តើអំណាចផ្តាច់ការនិយមកំពុងតែរៀបចំផែនការត្រលប់មកវិញ?» វ៉ាស៊ីងតោន ឌីស៊ី ក្រុមប្រឹក្សាអាត្លង់ទិច, ឆ្នាំ២០១៥។

ធន្ធៈគួបផិបក្ខក្នុងការប្រើប្រាស់ហិង្សា។ «ការតស៊ូអហិង្សាអាចមានប្រសិទ្ធភាព តែសម្រាប់គូសត្រូវ ដែលស្លូត និងមិនសូវឆៅឆាវ» ជាអ្វីដែលតែងតែត្រូវបាននិយាយដដែលៗ ប៉ុន្តែពួកគេភ្លេចពីជ័យជំនះលើរបបរើសអើងពូជសាសន៍នៅអាហ្វ្រិកខាងត្បូង ភីណូឆេត នៅស៊ីលី ម៉ាកូស នៅហ្វីលីពីន ឬក៏របបកុំម្មុយនីស្តនៅប៉ូឡូញ។ ឧទាហរណ៍ថ្មីៗ មានដូចជា ហូសនី មូបារ៉ាក់ នៅអេហ្ស៊ីប និងបេនអាលី នៅទុយនីស៊ី។ របបទាំងអស់នេះ មិនអាចចាត់ទុកថាមិនឆៅឆាវ ស្លូតបូត ឬគ្មានធន្ធៈក្នុងការបង្ក្រាបដោយខ្លាំងក្លានោះទេ។

ឧទារហណ៍បែបគុណភាពទាំងនេះ ត្រូវបានគាំទ្រដោយការវិភាគបែបបរិមាណ។ ក្នុងឆ្នាំ២០០៨ អង្គការហ្វ្រីដុម ហៅស៍ បានចេញផ្សាយការសិក្សាស្រាវជ្រាវដែលពិនិត្យមើលកត្តារចនាសម្ព័ន្ធជាច្រើន និងឥទ្ធិពលនៃកត្តាទាំងនោះមកលើការតស៊ូដោយពលរដ្ឋ ក្នុងស្ថានភាពអន្តរកាលចំនួន ៦៤ នៃរដ្ឋាភិបាលផ្តាច់ការចាប់ពីឆ្នាំ ១៩៧៥ ដល់ ២០០៦។ នេះគឺជាការដកស្រង់នៃសេចក្តីសន្និដ្ឋានសំខាន់៖

> ...ទាំងកត្តាមជ្ឈដ្ឋាន ឬកត្តានយោបាយដែលត្រូវបានពិនិត្យមើលក្នុងការសិក្សានេះពុំមានឥទ្ធិពលសំខាន់ទៅលើភាពជោគជ័យ ឬបរាជ័យនៃចលនាការតស៊ូដោយពលរដ្ឋនោះទេ... ចលនាពលរដ្ឋភាគច្រើនអាចទទួលបានជោគជ័យក្នុងប្រទេសក្រីក្រ និងកំពុងអភិវឌ្ឍ ស្មើៗគ្នានឹងប្រទេសដែលអភិវឌ្ឍ និងមានទ្រព្យសម្បត្តិដែរ។ ការសិក្សានេះក៏ពុំបានរកឃើញភស្តុតាងសំខាន់ណាដែលបង្ហាញថាការបែកខ្ញែកគ្នារបស់ក្រុមជនជាតិដើមភាគតិច ឬក្រុមសាសនា មានឥទ្ធិពលសំខាន់ទៅលើលទ្ធភាពនៃការកកើតឡើងនៃការប្រឆាំងដោយពលរដ្ឋ។ ចំណែកឯប្រភេទនៃរបប ក៏ពុំមានផលជះសំខាន់ណាមួយលើលទ្ធភាពនៃចលនាដោយពលរដ្ឋ ក្នុងការទទួលបានការគាំទ្រដ៏ទូលំទូលាយផងដែរ។[3]

កត្តាតែមួយដែលត្រូវបានពិនិត្យក្នុងការសិក្សាស្រាវជ្រាវនេះ ដែលមានឥទ្ធិពលសំខាន់លើការកកើត និងលទ្ធផលនៃការតស៊ូដោយពលរដ្ឋ គឺការប្រមូលផ្តុំអំណាចរបស់រដ្ឋាភិបាល។ អ្នកនិពន្ធបានសរសេរថា៖

> ការសិក្សានេះ បានបង្ហាញថាការប្រមូលផ្តុំអំណាចកម្រិតខ្ពស់មានភាពទាក់ទងជាវិជ្ជមានជាមួយនឹងការលេចឡើងនៃចលនាពលរដ្ឋដ៏រស់រវើកដែលមានសក្តានុពល ក្នុងការតវ៉ាប្រឆាំងនឹងអាជ្ញាធរនៃរបបមួយ។ ការមើលបញ្ច្រាស់មកវិញក៏ហាក់ដូចជាបង្ហាញថាអ្វីដែលរកឃើញគឺពិត ៖ កម្រិតនៃ

[3] ម៉ាឆែន អេលេណរ អែគ្រៀន កាវ៉ាតនិកគី អាដ កុដឌីងតុន និង គ្រីស្តុបហ្វឺ វ៉លគឺ ឆ្នាំ២០០៨ «ការបង្កើតនូវមជ្ឈដ្ឋានសម្រាប់ចលនាពលរដ្ឋ និងកម្លាំងនៃអន្តរកាលលទ្ធិប្រជាធិបតេយ្យ» របាយការណ៍ពិសេស របស់ ហ្វ្រីដុម ហៅស៍ ថ្ងៃទី១៨ ខែកក្កដា ទំព័រទី១។

**ជំពូកនេះមាននៅក្នុង ៖ ម៉ាជីវ ប៊្យូយ និង ម៉ារៀ ជេ. ស្ទេហ្វិន, «តើអំណាចផ្តាច់ការនិយមកំពុងតែរៀបចំផែនការត្រលប់មកវិញ ?» វ៉ាស៊ីងតោន ឌីស៊ី ក្រុមប្រឹក្សាអាត្លង់ទិច, ឆ្នាំ២០១៥។**

វិមជ្ឈការរបស់រដ្ឋាភិបាលកាន់តែខ្ពស់ នោះក៏កាន់តែពុំសូវឃើញមានការកើនឡើងនៃចលនាដោយពលរដ្ឋដែលទទួលបានជោគជ័យនោះដែរ។[4]

ដូច្នេះ ខណៈពេលដែលការសិក្សានេះរកឃើញលក្ខខណ្ឌមជ្ឈដ្ឋានមួយ ដែលជះឥទ្ធិពលទៅលើគន្លងនៃចលនាតស៊ូដោយពលរដ្ឋ ការរកឃើញជាទូទៅ បានទម្លាក់ចោលនូវការអះអាងដែលថាលក្ខខណ្ឌ គឺជាកត្តាកំណត់លទ្ធផលនៃជម្លោះ។

រយៈពេលបីឆ្នាំក្រោយមក ក្នុងសៀវភៅដែលទទួលបានជ័យលាភី ឆ្នាំ២០១១ របស់ពួកគេ ដែលមានចំណងជើងថា «ហេតុអ្វីបានជាការតស៊ូដោយពលរដ្ឋមានប្រសិទ្ធភាព ៖ តក្កវិជ្ជាយុទ្ធសាស្ត្រនៃជម្លោះអហិង្សា» អ្នកនិពន្ធ អេរីកា ឈើណូវិត និងម៉ារៀ ស្ទេហ្វិន បានធ្វើការវិភាគយ៉ាងម៉ត់ចត់លើយុទ្ធនាការហិង្សា និងអហិង្សាចំនួន ៣២៣ ដែលបានតវ៉ានឹងរដ្ឋាភិបាលកាន់អំណាចរវាងឆ្នាំ ១៩០០ ដល់ ២០០៦។[5] របកគំហើញដែលពុំធ្លាប់ឃើញពីមុនមក បានបង្ហាញថាយុទ្ធនាការអហិង្សាទទួលបានជោគជ័យ ៥៣% ក្នុងអំឡុងពេលនៃការសិក្សា ធៀបនឹង ២៦% នៃយុទ្ធនាការហិង្សាក្នុងរយៈពេលដូចគ្នា។[6] ពួកគេក៏បានរកឃើញថា ខណៈដែលការបង្ក្រាបរបស់រដ្ឋ និងកត្តាជារចនាសម្ព័ន្ធផ្សេងទៀតអាចជះឥទ្ធិពលមកលើទិដ្ឋភាព នៃភាពជោគជ័យរបស់យុទ្ធនាការតស៊ូដោយពលរដ្ឋ (ទោះបីជាញឹកញាប់អាចនឹងតិចជាងអ្វីដែលបានសន្មត ក្នុងករណីនៃការបង្ក្រាបដោយហិង្សារបស់រដ្ឋ ការធ្វើបែបនោះកាត់បន្ថយអត្រាជោគជ័យត្រឹមតែ ៣៥% ប៉ុណ្ណោះ) ពួកគេបានរកឃើញថាពុំមានលក្ខខណ្ឌជារចនាសម្ព័ន្ធដែលជាកត្តាកំណត់លទ្ធផលនៃចលនានោះទេ។[7] បន្ទាប់ពីការវាយតម្លៃទិន្នន័យគ្រប់ជ្រុងជ្រោយរួចមក ពួកគេបានសន្និដ្ឋានថា «ភស្តុតាងបានលើកឡើងថា ការតស៊ូដោយពលរដ្ឋតែងតែទទួលបានជោគជ័យ ដោយមិនគិតពីលក្ខខណ្ឌមជ្ឈដ្ឋាន ដែលមនុស្សជាច្រើនតែងតែភ្ជាប់ជាមួយនឹងចលនាអហិង្សាដែលបរាជ័យនោះទេ»។[8]

លទ្ធផលទាំងនេះលាតត្រដាងការសន្មតមិនត្រឹមត្រូវ ដែលជាការវិនិច្ឆ័យទូទៅដោយផ្អែកលើ ការតស៊ូដោយពលរដ្ឋ ។ ជំនាញ និងជម្រើសយុទ្ធសាស្ត្រ ជាញឹកញាប់តែងតែមានសារៈសំខាន់ជាងលក្ខខណ្ឌក្នុងការកំណត់លទ្ធផលនៃជម្លោះទាំងអស់នេះ។ ចំណុចនេះ តាមពិតទៅមិនគួរឱ្យភ្ញាក់ផ្អើលប៉ុន្មាននោះទេ នៅ

---

[4] ដូចខាងលើ ទំព័រទី១។

[5] ឈើណូវិត, អេរីកា និង ម៉ារៀ ស្ទេហ្វេន, ២០១១ «ហេតុអ្វីបានជាការតស៊ូដោយពលរដ្ឋមានប្រសិទ្ធភាព៖ តក្កវិជ្ជាយុទ្ធសាស្ត្រនៃជម្លោះអហិង្សា», ញូវយ៉កសារព័ត៌មាននៃសាកលវិទ្យាល័យកូឡុំប៊ី ទំព័រទី៦

[6] ដូចខាងលើ ទំព័រទី៩

[7] ដូចខាងលើ ទំព័រទី៦៨

[8] ដូចខាងលើ ទំព័រទី៦២

**ជំពូកនេះមាននៅក្នុង ៖ ម៉ាជីវ ប៊ូរ៉ូយ និង ម៉ារៀ ជេ. ស្ទេហ្វិន, «តើអំណាចផ្តាច់ការនិយមកំពុងតែរៀបចំផែនការត្រលប់មកវិញ?» វ៉ាស៊ីងតោន ឌីស៊ី ក្រុមប្រឹក្សាអាត្លង់ទិច, ឆ្នាំ២០១៥។**

ពេលដែលយើងពិចារណាមើលថា សេចក្តីសម្រេចចិត្តផ្អែកលើយុទ្ធសាស្ត្រដំបូងបង្អស់ នៃគូប្រជែងដែលជាជនផ្តាច់ការ គឺថាតើត្រូវវាយប្រហារដោយរបៀបណា។ ចំណុចនេះក៏សមហេតុផលក្នុងការរំពឹងថា ប្រសិនបើលក្ខខណ្ឌខាងក្រៅ គឺជាគន្លឹះក្នុងការកំណត់លទ្ធផល ដូច្នេះ ជម្រើសយុទ្ធសាស្ត្រអំពីរបៀបតស៊ូរបស់ពលរដ្ឋដែលតតាំងនឹងជនផ្តាច់ការនោះនឹងគ្មានសារៈសំខាន់ទេ ឯអត្រាជោគជ័យរវាងជម្លោះហិង្សា និងអហិង្សាក្នុងរយៈពេលកន្លងមក និងក្នុងករណីជាច្រើន គួរតែមានចំនួនស្មើគ្នា។

ប៉ុន្តែ នេះមិនមែនជាអ្វីដែលទិន្នន័យបានចង្អុលបង្ហាញនោះទេ។ ចាប់តាំងពីឆ្នាំ១៩០០ ដល់ ២០០៦ ចលនាអំណាចប្រជាពលរដ្ឋទទួលបានជោគជ័យច្រើនជាងពីរដង ហើយករណីសិក្សាថ្មីៗបង្ហាញថា ភាពខុសគ្នានៃអត្រាជោគជ័យពុំមានការផ្លាស់ប្តូរច្រើននោះទេ។[9] អ្នកខ្លះអាចនឹងដេញដោលចំណុចនេះ ដោយបញ្ជាក់ថាការតស៊ូដោយពលរដ្ឋរើសសមរភូមិដែលងាយស្រួលយកឈ្នះ ប៉ុន្តែ ឈើណូវិត និងស្ទេហ្វិន បានត្រៀមចំពោះការអះអាងបែបនេះ និងបានបង្ហាញថា «...ភាគច្រើនលើសលុបនៃយុទ្ធនាការអហិង្សាបានលេចឡើងក្នុងរបបផ្តាច់ការ... ដែលសូម្បីតែការប្រឆាំងនឹងរដ្ឋាភិបាលដោយសន្តិវិធី ក៏អាចបង្កផលវិបាកធ្ងន់ធ្ងរដែរ។»[10]

សេដ្ឋវិទូ ដែលទទួលបានពានរង្វាន់ណូបែល ថូម៉ាស ហ្សែលលីង បានទស្សន៍ទាយត្រូវ ក្នុងអត្ថបទដែលលោកបានសរសេរកាលពីជាង ៥០ឆ្នាំមុន ក្នុងសៀវភៅ «ការតស៊ូដោយពលរដ្ឋ ជាការការពារជាតិ៖ សកម្មភាពអហិង្សាប្រឆាំងនឹងការរុករាន»។ នេះជាអ្វីដែលលោកបានសន្និដ្ឋាន៖

> ជនផ្តាច់ការ និងអ្នកដែលត្រូវបានគាបសង្កត់ តែងតែស្ថិតក្នុងតំណែងដែលប្រហាក់ប្រហែលគ្នា។ អ្នកដែលត្រូវបានគាបសង្កត់ អាចបដិសេធជនផ្តាច់ការនូវរឿងជាច្រើនដែលជនផ្តាច់ការនោះចង់ធ្វើ ពួកគេអាចធ្វើបាន តែប្រសិនបើពួកគេមានការរៀបចំដែលមានវិន័យក្នុងការបដិសេធកិច្ចសហប្រតិបត្តិការណ៍។ ហើយជនផ្តាច់ការក៏អាចបដិសេធក្រុមដែលត្រូវបានគាបសង្កត់ នូវអ្វីដែលពួកគេចង់បានដែរ គេអាចបដិសេធបានតាមរយៈការប្រើប្រាស់កម្លាំងតាមការបញ្ជា... វាគឺជាស្ថានភាព

[9] ឈើណូវិត អេរីកា ឆ្នាំ២០១៤ «និន្នាការក្នុងការតស៊ូដោយពលរដ្ឋ និងការឆ្លើយតបរបស់អំណាចផ្តាច់ការ» គម្រោងអនាគតនៃអំណាចផ្តាច់ការនិយម របស់ក្រុមប្រឹក្សាអាត្លង់ទិក ថ្ងៃទី១៥ ខែមេសា

[10] ឈើណូវិត, អេរីកា និង ម៉ារៀ ស្ទេហ្វេន, ២០១១ «ហេតុអ្វីបានជាការតស៊ូដោយពលរដ្ឋមានប្រសិទ្ធភាព៖ តក្កវិជ្ជាយុទ្ធសាស្ត្រនៃជម្លោះអហិង្សា», ញូវយ៉ក សារព័ត៌មាននៃសាកលវិទ្យាល័យកូឡុំប៊ី ទំព័រទី៦៦

> នៃការតថ្លៃដោយភាគីម្ខាងៗ ប្រសិនបើមានវិន័យ និងការរៀបចំគ្រប់គ្រាន់ អាចបដិសេធអ្វីជាច្រើន ដែលភាគីម្ខាងទៀតចង់បាន ហើយនឹងនៅចាំមើលថាតើនរណាម្នាក់នឹងឈ្នះ។[11]

យោងតាម ហ្សែលលីង យុទ្ធវិធីដែលត្រូវបានជ្រើសរើសដោយអ្នកតស៊ូដែលជាពលរដ្ឋ មានថ្លៃចំណាយ និងផលចំណេញ ដូចនឹងយុទ្ធវិធីដែលប្រើប្រាស់ដោយគូប្រជែងដែលជាជនផ្តាច់ការរបស់ពួកគេដូចគ្នាដែរ។ អ្នកឈ្នះ គឺជាបុគ្គលសំខាន់ ដែលបែងចែកថ្លៃចំណាយ និងផលចំណេញបានយ៉ាងមានប្រសិទ្ធភាពបំផុតសម្រាប់ភាគីរបស់ខ្លួន។ អ្នកដឹកនាំការតស៊ូដោយពលរដ្ឋដែលមានជំនាញ ចង់បង្កើតនូវការរំខានដែលធ្វើឱ្យមានការចុះចូលច្រើនបំផុត ហើយក៏ចង់ឱ្យយុទ្ធវិធីដែលប្រើប្រាស់ផ្តល់ផលល្អប្រសើរបំផុត មានន័យថាប្រើការរំខានទ្រង់ទ្រាយតូចតែអាចនាំឱ្យមានការចុះចូលច្រើន។ ជនផ្តាច់ការដែលមានជំនាញ ត្រូវការពង្រឹងការស្តាប់បង្គាប់ ដែលជាញឹកញាប់គឺការប្រើហិង្សា ហើយក៏ចង់ធ្វើដោយមានប្រសិទ្ធិភាពខ្ពស់ មានន័យថាប្រើប្រាស់ហិង្សាតិចតួចបំផុត តែអាចនាំមកនូវការស្តាប់បង្គាប់ច្រើនបំផុត។ ការបូកបន្តគ្នានៃការចុះចូល ក៏ដូចជា ការស្តាប់បង្គាប់ អាចកំណត់ថានរណាជាអ្នកឈ្នះ។

## បញ្ជីចំណុចដែលត្រូវធ្វើ

ប្រសិនបើជំនាញ និងជម្រើសយុទ្ធសាស្ត្រ ជាអ្វីដែលមានឥទ្ធិពលបំផុតមកលើលទ្ធផលនៃចលនាការតស៊ូដោយពលរដ្ឋ នោះយើងគួរតែអាចកំណត់នូវសមត្ថភាព ជំនាញ និងជម្រើសរួមគ្នា ក្នុងចលនាជាច្រើនដែលបង្កើតជាភាគបែងនៃភាពជោគជ័យ។ ទិដ្ឋភាពជាច្រើននៃចលនា ដែលអាចត្រូវបានវិភាគ ប៉ុន្តែនៅពេលដែលយើងចម្រោះនូវអញ្ញត្តិជាច្រើន យើងឃើញថាសមត្ថភាពសំខាន់បី នៃចលនាតស៊ូដោយពលរដ្ឋដែលទទួលជោគជ័យមានដូចជា៖

១. លទ្ធភាពនៃការបង្រួបបង្រួមមនុស្ស
២. ផែនការប្រតិបត្តិ
៣. វិន័យអហិង្សា

នៅពេលដែលសមត្ថភាពទាំងនេះ មាននៅក្នុងចលនាតស៊ូដោយពលរដ្ឋ វាត្រួសត្រាយផ្លូវសម្រាប់និន្នាការដ៏មានអំណាចសំខាន់ៗបី ដែលមានឥទ្ធិពលខ្លាំងទៅលើភាពជោគជ័យនៃចលនាដែរ។ និន្នាការទាំងនោះមាន៖

[11] ថូម៉ាស ស៊ី ហ្សែលលីង ឆ្នាំ១៩៦៨ «សំណួរខ្លះស្តីពីការការពារដោយពលរដ្ឋ» ក្នុង អាដាម រ៉ូប៊ឺត និពន្ធនាយក «ការតស៊ូដោយពលរដ្ឋ ជាការការពារជាតិ៖ សកម្មភាពអហិង្សាប្រឆាំងនឹងការរុករាន» ហារីសប៊ឺក ភីអេ៖ សៀវភៅស្តែកផូល ទំព័រ ៣០៤។

**ជំពូកនេះមាននៅក្នុង ៖ ម៉ាជីរ ប៊្យូយ និង ម៉ារៀ ជេ. ស្ទេហ្វិន, «តើអំណាចផ្តាច់ការនិយមកំពុងតែរៀបចំផែនការត្រលប់មកវិញ?» វ៉ាស៊ីងតោន ឌីស៊ី ក្រុមប្រឹក្សាអាត្លង់ទិច, ឆ្នាំ២០១៥។**

១. ការបង្កើនការចូលរួមរបស់ប្រជាពលរដ្ឋសាមញ្ញក្នុងការតស៊ូដោយពលរដ្ឋ
២. កាត់បន្ថយនូវផលជះនៃការបង្ក្រាប និងបង្កើនលទ្ធភាពនៃលទ្ធផលដែលផ្ទុយពីការរំពឹងទុករបស់គូបដិបក្ខ
៣. បង្កើនការចុះចូលពីចលនានៃគូបដិបក្ខ

រួមបញ្ចូលគ្នា យើងសំដៅលើគុណលក្ខណៈទាំងបី និងនិន្នាការទាំងបីនេះជា «បញ្ជីចំណុចដែលត្រូវធ្វើ»។ យើងជឿថាការសម្រេចបាននូវគុណលក្ខណៈ និងនិន្នាការទាំងនេះ អាចបង្កើនលទ្ធភាពជោគជ័យរបស់ចលនាបានយ៉ាងធំសម្បើម។ ក្នុងករណីនេះ បញ្ជីចំណុចដែលត្រូវធ្វើ មិនមែនជារូបមន្តដែលធានាលទ្ធផលច្បាស់នោះទេ ប៉ុន្តែជាក្របខណ្ឌដែលជួយឱ្យបុគ្គលអាចរៀបចំការគិត និងបង្កើនប្រសិទ្ធភាពរបស់ពួកគេ។

មកដល់ចំណុចនេះ មុខងារមួយនៃបញ្ជីចំណុចដែលត្រូវធ្វើ គឺដើម្បីចៀសអារម្មណ៍វង្វេងស្មារតីដែលអាចកើតមានឡើងក្នុងអំឡុងពេលនៃជម្លោះ។ ភាពស្មុគស្មាញ ជាបញ្ហាប្រឈមដ៏ខ្លាំងបំផុតមួយ ដែលចលនាតស៊ូដោយពលរដ្ឋជួបប្រទះ ហើយក្នុងអព្ទនៃជម្លោះ អាចនឹងពិបាកមើលឃើញថាតើកត្តាណាមួយដែលសំខាន់បំផុតក្នុងការសម្រេចចិត្ត។ យើងរក្សាទុកចំណុចនោះ ក្នុងករណីដែលសកម្មជន ឬអ្នកសង្កេតការណ៍ពីខាងក្រៅមានបំណងចង់វាយតម្លៃទិដ្ឋភាពនៃចលនា សំណួរសួរថា តើសមត្ថភាពទាំងបី និងនិន្នាការទាំងបីនេះនៅលើបញ្ជីចំណុចដែលត្រូវធ្វើ ដែលបានបង្ហាញ នឹងផ្តល់នូវមូលដ្ឋានគ្រឹះរឹងមាំសម្រាប់វាយតម្លៃស្ថានភាពបច្ចុប្បន្ន ភាពខ្លាំង ភាពខ្សោយ និងទិដ្ឋភាពជោគជ័យរបស់ចលនាមួយ។

យើងលម្អិតនូវបញ្ជីចំណុចដែលត្រូវធ្វើដូចខាងក្រោម៖

## ១. លទ្ធភាពនៃការបង្រួបបង្រួមមនុស្ស

ជនផ្តាច់ការ ជាអ្នកអនុវត្តដ៏ជំនាញនៃការបំបែកបំបាក់ និងគ្រប់គ្រង ហើយអ្នកដែលចង់តតាំងនឹងជនផ្តាច់ការទាំងនេះ ត្រូវតែមានជំនាញផ្នែកបង្រួបបង្រួម។ ការកសាង និងរក្សាសាមគ្គីភាព មានទិដ្ឋភាពជាច្រើន តែទិដ្ឋភាពដែលសំខាន់បំផុតនៃការធ្វើបែបនោះគឺការបង្កើតទស្សនៈវិស័យដែលមានរួមគ្នា និងបរិយាបន្នសម្រាប់ចលនាតស៊ូដោយពលរដ្ឋ។ ការសម្រេចបានចំណុចនេះ គឺចាំបាច់ដែលអ្នករៀបចំចលនាមានចំណេះដឹងស៊ីជម្រៅពីទុក្ខកង្វល់ បំណងប្រាថ្នា វប្បធម៌ និងតម្លៃរបស់ប្រជាពលរដ្ឋសាមញ្ញផ្សេងៗគ្នា ជាក្រុមដែលពួកគេមានបំណងកៀរគរ។ ចំណេះដឹងនេះបង្កើតជាមូលដ្ឋានគ្រឹះនៃការបង្កើត និងទំនាក់ទំនង

ជំពូកនេះមាននៅក្នុង ៖ ម៉ាជីរ ប៊្លូយ និង ម៉ារៀ ជេ. ស្ទេហ្វិន, «តើអំណាចផ្តាច់ការនិយមកំពុងតែរៀបចំផែនការត្រលប់មកវិញ?» វ៉ាស៊ីងតោន ឌីស៊ី ក្រុមប្រឹក្សាអាត្លង់ទិច, ឆ្នាំ២០១៥។

ទស្សនៈវិស័យដែលទាក់ទាញការគាំទ្រ និងកៀរគរមនុស្សឱ្យបានទូលំទូលាយ។ ទស្សនៈវិស័យដែលមានប្រសិទ្ធភាពឆ្លុះបញ្ចាំងបទពិសោធន៍ និងអារម្មណ៍ផ្ទាល់ខ្លួនរបស់បុគ្គលសាមញ្ញ និងប្រមូលផ្តុំការចូលរួមជាសមូហភាពក្នុងការតស៊ូដោយពលរដ្ឋ។

ទិដ្ឋភាពសំខាន់មួយទៀត នៃការកសាងសាមគ្គីភាព គឺវត្តមាននៃ ភាពជាអ្នកដឹកនាំ និងការរៀបចំរចនាសម្ព័ន្ធដែលមានភាពស្របច្បាប់។ ការចូលរួមក្នុងចលនា គឺដោយស្ម័គ្រចិត្ត ហើយអ្នកដឹកនាំក៏ពុំអាចចេញបញ្ជា និងមានអំណាចត្រួតត្រាផ្លូវការលើប្រជាពលរដ្ឋដែលបានកៀរគរនោះដែរ។ ចំណុចនេះមានន័យថាសេចក្តីសម្រេចចិត្តក្នុងចលនាត្រូវតែសម្រេច និងអនុវត្តតាមរបៀបដែលអាចធ្វើឱ្យសាធារណជនដែលត្រូវបានស្នើសុំឱ្យចូលរួមមានអារម្មណ៍ថាមានភាពស្របច្បាប់។ ចលនានីមួយៗបង្កើតវិធីផ្សេងៗ ក្នុងការធ្វើរបៀបនេះ អ្នកខ្លះធ្វើដោយមានឋានានុក្រមបន្តិច ខ្លះធ្វើទៅតាមវិធីបែបវិមជ្ឈការបន្តិច ហើយអ្នកខ្លះទៀតធ្វើដោយប្រើប្រាស់ចំណុចទាំងពីររួមគ្នា។ ទោះបីជាមានភាពជាអ្នកដឹកនាំ និងការរៀបចំរចនាសម្ព័ន្ធនៃចលនាបែបណាក៏ដោយ ក៏មានទម្រង់ផ្សេងៗគ្នានៃភាពជាអ្នកដឹកនាំក្នុងចលនាជាច្រើន ហើយសាមគ្គីភាព ពាក់ព័ន្ធនឹងការបង្រួបបង្រួមនៃភាពជាអ្នកដឹកនាំទាំងនេះ។ ចំពោះអ្នកដឹកនាំថ្នាក់ជាតិម្នាក់ៗ ទាំងអ្នកដែលមានប្រជាប្រិយភាព ឬអ្នកដែលមានតែតំណែង តែងតែមានអ្នកដឹកនាំមូលដ្ឋាន ដែលតម្រូវឱ្យមានជំនាញខ្ពស់ក្នុងការបង្កើតសម្ព័ន្ធមិត្ត ការចរចា និងការប្រមូលផ្តុំចំណាប់អារម្មណ៍ក្នុងចំណោមក្រុមផ្សេងៗគ្នា។ នេះគឺជាលទ្ធភាពនៃអ្នកដឹកនាំផ្សេងៗ នៅកម្រិតខុសៗគ្នា (មូលដ្ឋាន ឬថ្នាក់ជាតិ) ពីផ្នែកផ្សេងៗក្នុងប្រទេស តំណាងឱ្យក្រុមខុសៗគ្នា ដើម្បីធ្វើការជាមួយគ្នាក្នុងការរក្សាសាមគ្គីភាពឱ្យបានក្នុងរយៈពេលវែង។

យើងអាចមើលឃើញនូវភស្តុតាងនៃទិដ្ឋភាពទាំងនេះ នៃសាមគ្គីភាព ក្នុងការតស៊ូដោយពលរដ្ឋដែលត្រូវបានប្រើប្រាស់ដោយចលនាប្រឆាំងការរើសអើងពូជសាសន៍ នៅអាហ្វ្រិកខាងត្បូងក្នុងឆ្នាំ១៩៨០។ មានក្រុមពលរដ្ឋនៅមូលដ្ឋានជាច្រើនរយក្រុម បានដុះពន្លកឡើងក្នុងអំឡុងទស្សវត្សរ៍នោះ ដើម្បីតស៊ូមតិទាមទារឱ្យបំពេញតម្រូវការថ្នាក់ក្រុង ដូចជា ទឹកស្អាត និងការទទួលបានសេវា ស្របពេលជាមួយគ្នានោះក៏រួបរួមគ្នាក្រោមទស្សនៈវិស័យរួមមួយក្នុងការបញ្ចប់ការរើសអើងពូជសាសន៍ និងទទួលបានការផ្សះផ្សាថ្នាក់ជាតិ។ ក្រុមពលរដ្ឋទាំងនេះ ដែលបញ្ចូលគ្នាក្លាយទៅជា រណសិរ្សលទ្ធិប្រជាធិបតេយ្យរួបរួម មានអ្នកដឹកនាំមូលដ្ឋាន ដែលអាចដឹកនាំនូវយុទ្ធវិធីវិមជ្ឈការយ៉ាងមានប្រសិទ្ធភាព (ដូចជា ពហិការអតិថិជន) សម្រាប់បញ្ហានៅមូលដ្ឋាន ហើយស្របពេលជាមួយគ្នានោះ ក៏មានទំនាក់ទំនង និងសហប្រតិបត្តិការជាមួយរចនាសម្ព័ន្ធរៀបចំកម្រិតធំ និងភាពជាអ្នកដឹកនាំនៃចលនាថ្នាក់ជាតិ។

ជំពូកនេះមាននៅក្នុង ៖ ម៉ាធីវ ប៊ូរ៉ូយ និង ម៉ារៀ ជេ. ស្ទេហ្វិន, «តើអំណាចផ្តាច់ការនិយមកំពុងតែរៀបចំផែនការត្រលប់មកវិញ?» វ៉ាស៊ីងតោន ឌីស៊ី ក្រុមប្រឹក្សាអាត្លង់ទិច, ឆ្នាំ២០១៥។

## ២. ផែនការប្រតិបត្តិ

ការធ្វើការតស៊ូដោយមានប្រសិទ្ធភាព គឺមានភាពស្មុគស្មាញខ្លាំងជាងការសន្មតទូទៅ។ រូបភាពដែលចូលក្នុងខួរក្បាល ពេលដែលមនុស្សគិតពីការតស៊ូដោយពលរដ្ឋ គឺការធ្វើបាតុកម្ម ក៏ប៉ុន្តែនោះគ្រាន់តែជាមធ្យោបាយមួយក្នុងចំណោមយុទ្ធវិធីរាប់រយដែលអាចប្រើប្រាស់បានប៉ុណ្ណោះ។ ចលនាដែលមានប្រសិទ្ធភាពបំផុត យល់ថាយុទ្ធវិធីអ្វីដែលត្រូវជ្រើសរើស ពេលណា កន្លែងណា របៀបណា គួរតែអនុវត្តដោយនរណា គួរតែដៅមុខសញ្ញាលើអ្វី និងថាតើត្រូវរៀបចំលំដាប់លំដោយបែបណាក្នុងចំណោមយុទ្ធវិធីផ្សេងៗទៀត។

ការឆ្លើយនឹងសំណួរទាំងអស់នេះឱ្យបានគ្រប់គ្រាន់ តម្រូវឱ្យមានការធ្វើផែនការផ្អែកលើការវិភាគដោយលម្អិតអំពី ភាពខ្លាំង ភាពខ្សោយ ឱកាស និងការគំរាមកំហែងទាំងរបស់ចលនា និងគូបដិបក្ខ ក៏ដូចជា ការវាយតម្លៃមជ្ឈដ្ឋានជម្លោះ និងភាគីអព្យាក្រឹត ឬក៏ភាគីមិនច្បាស់លាស់ (រួមទាំងសមាជិកនៃសហគមន៍អន្តរជាតិ) ដែលអាចជះឥទ្ធិពលដល់ជម្លោះដែរ។ យោងតាមព័ត៌មានទាំងនេះ ចលនាអាចបង្កើតគោលបំណងរយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង ព្រមទាំងផែនការដែលឆ្លើយតបទៅនឹងគោលបំណងទាំងនោះ។ ខណៈដែលផែនការនឹងមានការវិវត្តពីពេលមួយទៅពេលមួយទៀត ដែលឆ្លើយតបទៅនឹងព្រឹត្តិការណ៍ជាក់ស្តែង (ដូចជាផែនការផ្សេងៗទៀតដែរ) ដំណើរការធ្វើផែនការ និងការគិត គឺសំខាន់សម្រាប់អ្នកចូលរួមចលនា ដើម្បីបង្កើត ជាជាងផែនការដែលជាក់លាក់ណាមួយ។

ជាបន្ទាប់បន្សំ នៅក្នុងផែនការប្រតិបត្តិនេះហើយដែលយើងឃើញនូវចំណុចប្រសព្វច្បាស់លាស់រវាងជំនាញ និងលក្ខខណ្ឌក្នុងជម្លោះ។ មូលដ្ឋាននៃការធ្វើផែនការប្រតិបត្តិ គឺជាការវាយតម្លៃលក្ខខណ្ឌផ្សេងៗទាំងអំណោយផល និងមិនអំណោយផល ប្រឈមមុខដោយចលនាមួយ។ ក្រោយមក ចលនាធ្វើផែនការដើម្បីទាញយកប្រយោជន៍ចេញពីលក្ខខណ្ឌដែលអំណោយផល និងយកឈ្នះ កែប្រែ ឬក៏ចៀសវៀងលក្ខខណ្ឌអាក្រក់តាមរយៈជំនាញ និងជម្រើសយុទ្ធសាស្ត្រ។

ឧទាហរណ៍ជាក់ស្តែងនៃផែនការប្រតិបត្តិ ត្រូវបានឃើញក្នុងចលនាសាមគ្គីភាព នៅប៉ូឡូញ ឆ្នាំ១៩៨០។ ការយល់ពីភាពខ្លាំង និងសមត្ថភាពរបស់ពួកគេ កម្មករអាចបញ្ជាក់យ៉ាងច្បាស់ពីតម្រូវការដែលមានភាពជាក់លាក់ផ្នែកនយោបាយ និងមានអំណាច ដើម្បីទាមទារបង្កើតសហជីពឯករាជ្យ (ប៉ុន្តែបានទប់ស្កាត់ខ្លួនដោយមិនអំពាវនាវឱ្យមានការបញ្ចប់ការគ្រប់គ្រងបែបកុំម្មុយនីស្ត ជាគោលដៅមួយដែលហាក់ដូចជាមិនអាចសម្រេចបាននៅពេលនោះ) ប្រមូលផ្តុំកម្លាំងរបស់ពួកគេក្នុងការរៀបចំកម្មករ និងសាមគ្គីភាពក្នុងចំណោមក្រុមកម្មករចម្រុះ ប្រឆាំងនឹងភាពទន់ខ្សោយផ្នែកសេដ្ឋកិច្ច និងកង្វះភាពស្របច្បាប់របស់គូ

ជំពូកនេះមាននៅក្នុង ៖ ម៉ាជីវ ប៊ូរ៉ូយ និង ម៉ារៀ ជេ. ស្ទេហ្វិន, «តើអំណាចផ្តាច់ការនិយមកំពុងតែរៀបចំផែនការត្រលប់មកវិញ ?» វ៉ាស៊ីងតោន ឌីស៊ី ក្រុមប្រឹក្សាអាត្លង់ទិច, ឆ្នាំ២០១៥។

បដិបក្ខ និងជ្រើសយកយុទ្ធវិធីដែលមានប្រសិទ្ធភាព នៃការធ្វើកូដកម្មតាមរយៈកាន់កាប់កន្លែងការងាររបស់ពួកគេ (ជំនួសឱ្យការដើរក្បួននៅខាងក្រៅកន្លែងធ្វើការ ដែលធ្វើឱ្យគេរងការបង្ក្រាប ហើយដែលគេបានសាកល្បងធ្វើកាលឆ្នាំមុនៗ)។ ចំណុចនេះ បន្ថែមពីលើដោយការពឹងផ្អែករបស់កម្មករលើស្ថាប័នដែលបានជ្រើសរើស ជាពិសេស សារព័ត៌មានបោះពុម្ពផ្សាយ និងសារព័ត៌មានបោះពុម្ពជាទៀងទាត់ឯករាជ្យ ដែលបានបង្កើតឡើងក្នុងទស្សវត្សរ៍មុន ដើម្បីសម្របសម្រួលនូវទំនាក់ទំនងរវាងទីក្រុង និងទីក្រុង។ តាមរយៈការជ្រើសរើសគោលបំណងយុទ្ធសាស្ត្រ គោលដៅដ៏សមរម្យ និងយុទ្ធវិធីដែលសមស្រប (ដូចជាកូដកម្មដើម្បីកាន់កាប់ និងការប្រើប្រាស់ស្ថាប័នដែលបានជ្រើសរើស) ដែលស្ថិតក្នុងកម្រិតសមត្ថភាពរបស់ពួកគេ ចលនាសាមគ្គីភាពនេះ បានក្លាយជាអ្នកដឹកនាំក្នុងមជ្ឈដ្ឋានជម្លោះយ៉ាងមានប្រសិទ្ធភាព ដោយបានយកឈ្នះលក្ខខណ្ឌអាក្រក់ៗ និងដើរទៅមុខឆ្ពោះទៅកាន់គោលដៅចុងក្រោយរបស់ពួកគេ ហើយនោះគឺ ប្រទេសប៉ូឡូញដែលមានប្រជាធិបតេយ្យ ដែលសម្រេចបាននៅឆ្នាំ១៩៨៩។[12]

## ៣. វិន័យអហិង្សា

ការរក្សានូវវិន័យអហិង្សា ជាលទ្ធភាពរបស់អ្នកតស៊ូក្នុងការប្រកាន់យកភាពអហិង្សា ទោះបីជាមានការផ្តើនគឺជាគ្រឹះដ៏សំខាន់របស់ចលនាតស៊ូដោយពលរដ្ឋដែលដំណើរការដោយកម្លាំង។ ជាមួយនឹងវិន័យអហិង្សា ចលនាបានបង្កើនការចូលរួមពីប្រជាពលរដ្ឋសាមញ្ញដល់ចំណុចអតិបរមា បង្កើនថ្លៃចំណាយសម្រាប់ការបង្ក្រាបរបស់គូបដិបក្ខ បង្កើនភាពដែលអាចទៅរួចថាការបង្ក្រាបនឹងជះផលអវិជ្ជមានបកមកវិញ និងហាក់ដូចជាអាចបង្កើតឱ្យមានការចុះចូលពីសសរស្តម្ភនៃការគាំទ្រសំខាន់ៗនៃគូបដិបក្ខ។ ដូចជាការស្រាវជ្រាវរបស់ ឈើណូវិត និងស្ទេហ្វិន បង្ហាញថា ផលប្រយោជន៍ទាំងអស់នេះ រួមចំណែកយ៉ាង សំខាន់ក្នុងភាពខុសគ្នានៃអត្រាភាពជោគជ័យ រវាងយុទ្ធនាការហិង្សា និងយុទ្ធនាការតស៊ូដោយពលរដ្ឋ។[13]

ការសម្រេចឱ្យបាននូវវិន័យអហិង្សា តម្រូវឱ្យចលនាទាំងនោះមានទំនុកចិត្តថាការតស៊ូដោយពលរដ្ឋជាមធ្យោបាយដែលមានប្រសិទ្ធភាពដើម្បីកាត់សេចក្តីនូវជម្លោះរបស់ពួកគេ។ ព័ត៌មានទាក់ទងនឹងរបៀបដែលការតស៊ូដោយពលរដ្ឋអាចបានជោគជ័យ និងកំណត់ត្រាប្រវត្តិសាស្ត្រនៃចលនាទាំងនេះអាច មានប្រយោជន៍ក្នុងករណីនេះ មានន័យថាជាយុទ្ធសាស្ត្រដ៏មានប្រសិទ្ធភាពដែលបង្កើតភាពជោគជ័យបន្ថែមទៀតជាបន្តបន្ទាប់ និងបង្ហាញថាការតស៊ូដោយពលរដ្ឋពិតជាមានប្រសិទ្ធភាពមែន។ ចលនានោះក៏ត្រូវ

[12] អែកឹមែន ភីទ័រ និង ដែក ឌូវ៉ល ឆ្នាំ២០០០ «កម្លាំងមួយដែលកាន់តែមានអំណាច ៖ សតវត្សរ៍មួយនៃជម្លោះអហិង្សា» ឡុងដ៍៖ សារព័ត៌មាន អេសធី ម៉ាទីន/ផាលក្រេវ ម៉ែកមីឡាន ទំព័រទី ១១៣ ដល់ ១៧៤

[13] ឈើណូវិត, អេរីកា និង ម៉ារៀ ស្ទេហ្វេន, ២០១១ «ហេតុអ្វីបានជាការតស៊ូដោយពលរដ្ឋមានប្រសិទ្ធភាព៖ តក្កវិជ្ជាយុទ្ធសាស្ត្រនៃជម្លោះអហិង្សា», ញូវយ៉កសារព័ត៌មាននៃសាកលវិទ្យាល័យកូឡុំប៊ី ទំព័រទី៣០ ដល់ ៦១

ក្សាវិន័យអហិង្សាតាមរយៈការបង្កើតវប្បធម៌ និងបទដ្ឋានដែលពង្រឹងវិន័យទាំងនេះផងដែរ។ ឧទាហរណ៍ ចលនា អដប់ នៅស៊ែប៊ី ដែលបានបណ្តេញ ស្លូបូដែន មីឡូសូវិក បានបណ្តុះបណ្តាលជាប្រព័ន្ធដល់សមាជិកថ្មី ដើម្បីឱ្យយល់ថាតើការតស៊ូដោយពលរដ្ឋអាចទទួលបានជោគជ័យដោយរបៀបណា និងហេតុអ្វីបានជាវាមានសារៈសំខាន់ក្នុងការរក្សាភាពអហិង្សា។

កិច្ចប្រឹងប្រែងទាំងនោះ មិនតម្រូវឱ្យចលនាលើកអំណះអំណាងប្រកបដោយសីលធម៌ អំពីការរក្សាភាពអហិង្សានោះទេ ប៉ុន្តែប្រជាពលរដ្ឋត្រូវតែពង្រឹងគ្នាទៅវិញទៅមកអំពីផលប្រយោជន៍ជាក់ស្តែងនៃវិន័យអហិង្សា ខណៈពេលនោះក៏ត្រូវចងចាំនូវករណី (ស៊ីរី គឺជាឧទាហរណ៍ដ៏សោកសៅដែលកើតឡើងថ្មីៗនេះ) ដោយសារតែខ្វះភាពអត់ធ្មត់ ឬខ្វះទំនុកចិត្តលើការតស៊ូដោយពលរដ្ឋ នាំឱ្យមានការផ្លាស់ទៅរកយុទ្ធវិធីហិង្សា ដែលទទួលបាននូវផលវិបាកដ៏អាក្រក់បំផុតដូចដែលបានទាយដឹងមុន។

## ៤. ការបង្កើនការចូលរួមរបស់ប្រជាពលរដ្ឋសាមញ្ញក្នុងការតស៊ូដោយពលរដ្ឋ

ការចូលរួមរបស់ប្រជាពលរដ្ឋធម្មតាក្នុងកម្រិតខ្ពស់ ក្នុងការតស៊ូដោយពលរដ្ឋ គឺអាចអះអាងបានថាជាអ្នកកំណត់ដ៏ធំបំផុតតែមួយអំពីភាពជោគជ័យរបស់ចលនា។[14] ចំណុចនេះ ពិតជាត្រឹមត្រូវ ដោយសារតែពេលដែលប្រជាពលរដ្ឋកាន់តែច្រើនពុំផ្តល់ការយល់ព្រម ឬក៏ការគោរពចំពោះរបបផ្តាច់ការនោះ ក៏កាន់តែធ្វើឱ្យរបបផ្តាច់ការនោះទន់ខ្សោយទៅ និងកាន់តែមានថ្លៃចំណាយច្រើនទៅៗសម្រាប់ជនផ្តាច់ការក្នុងការរក្សាការត្រួតត្រារបស់ខ្លួន។ បន្ថែមពីលើនោះ យើងជឿថាការបង្កើនការចូលរួមរបស់ប្រជាពលរដ្ឋធម្មតា នឹងបង្កើនឱកាសដែលការបង្ក្រាបនឹងជះផលអវិជ្ជមានបកមកវិញ ហើយភស្តុតាងបែបបរិមាណ បង្ហាញថាការចូលរួមរបស់ប្រជាពលរដ្ឋធម្មតាកាន់តែច្រើន បង្កើនលទ្ធភាពនៃការកើតមានឡើងនៃការចុះចូលពីអ្នកគាំទ្ររបស់គូបដិបក្ខកាន់តែច្រើនដែរ។[15]

ការបង្ហាញពីសារៈសំខាន់នៃការចូលរួមរបស់ប្រជាពលរដ្ឋធម្មតាក្នុងកម្រិតខ្ពស់ ដែលបដិវត្តន៍ នៅអេហ្ស៊ីប និងទុយនីស៊ី ឆ្នាំ២០១១ បង្កើតឱ្យមានការគាំទ្រយ៉ាងទូលំទូលាយក្នុងចំណោមក្រុមមកពីប្រភពផ្សេងៗ ទាំងបុរស និងស្ត្រី ក្រុមសាសនា និងក្រុមគ្រហស្ថ ក្មេង ក្រុមវ័យកណ្តាល និងមនុស្សចាស់ កម្មករថ្នាក់ទាប និងថ្នាក់កណ្តាល និងប្រជាពលរដ្ឋនៅទីប្រជុំជន និងជនបទ។ ផ្ទុយមកវិញ ទាំងចលនាសិស្សនិស្សិតនៅចិន ឆ្នាំ១៩៨៩ និងចលនាបៃតង ឆ្នាំ២០០៩ បានកៀរគរ និងចាប់យកការផ្សព្វផ្សាយនៅក្នុងសារព័ត៌មាន

[14] ដូចខាងលើ ទំព័រទី៣០ ដល់ ៦១

[15] ដូចខាងលើ ទំព័រទី៤៦ ដល់ ៤៩

ជំពូកនេះមាននៅក្នុង ៖ ម៉ាជីវ ប៊្លូយ និង ម៉ារៀ ជេ. ស្ទេហ្វិន, «តើអំណាចផ្តាច់ការនិយមកំពុងតែរៀបចំផែនការត្រលប់មកវិញ?» វ៉ាស៊ីងតោន ឌីស៊ី ក្រុមប្រឹក្សាអាត្លង់ទិច, ឆ្នាំ២០១៥។

រាប់សិបលាន ប៉ុន្តែពុំមានចលនាមួយណាអាចសម្រេចនូវគោលបំណងដែលបានកំណត់នោះទេ មួយភាគដោយសារតែចលនាទាំងពីរ សុទ្ធតែមិនបានបង្កើនឱ្យមានការចូលរួមរបស់ប្រជាពលរដ្ឋធម្មតាឱ្យបានទូលំទូលាយលើសពីក្រុមប្រជាសាស្ត្រដំបូងដែលបានចូលរួមជាមួយចលនាទាំងពីរនោះទេ។

ការសម្រេចបាននូវការចូលរួមកម្រិតខ្ពស់ ក្នុងចលនាតស៊ូដោយពលរដ្ឋ គឺជាលទ្ធផលនៃចំណុចទាំងបីដំបូងនៅលើបញ្ជីចំណុចដែលត្រូវធ្វើ។ ទស្សនៈវិស័យបង្រួបបង្រួមជួយធ្វើឱ្យការកៀរគរកាន់តែស្អិតរមួតនិងសកម្ម។ ផែនការប្រតិបត្តិ បណ្តុះនូវទំនុកចិត្ត និងផ្តល់យុទ្ធវិធីតាមលំដាប់លំដោយសម្រាប់ឆ្លើយតបទៅនឹងកម្រិតទទួលយកហានិភ័យរបស់អ្នកចូលរួម ពេលវេលាដែលមាន និងសមត្ថភាពក្នុងការលះបង់ដើម្បីចលនា។ យុទ្ធសាស្ត្រដែលមានប្រសិទ្ធភាព ផ្តល់ជម្រើសដល់អ្នកក្រ អ្នកមាន ក្មេង មនុស្សចាស់ និងមនុស្សគ្រប់គ្នាទាំងអស់ដើម្បីអាចធ្វើអ្វីម្យ៉ាងបាន តូច ឬធំ ដើម្បីគាំទ្រដល់ចលនា។ វិន័យអហិង្សាធានាថាមនុស្សគ្រប់គ្នាអាចចូលរួម (ផ្ទុយទៅនឹងការចូលរួមក្នុងការបះបោរហិង្សា គឺត្រូវតែជាមនុស្សប្រុសដែលមានកាយសម្បទាមាំមួន) និងមធ្យោបាយអហិង្សា គឺកាន់តែអាចទាក់ទាញចិត្តរបស់មនុស្សគ្រប់គ្នានៅក្នុងសង្គមទាំងមូល។

## ៥. កាត់បន្ថយនូវផលជះនៃការបង្ក្រាប និងបង្កើនលទ្ធភាពនៃលទ្ធផលដែលផ្ទុយពីការរំពឹងទុករបស់គូបដិបក្ខ

ឧបករណ៍ដ៏មានអំណាចបំផុតរបស់អំណាចផ្តាច់ការ គឺសមត្ថភាពបង្ក្រាប ហើយចលនាដែលមានប្រសិទ្ធភាពបានដឹងពីរបៀបក្នុងការកាត់បន្ថយផលជះនៃការបង្ក្រាប ស្របពេលជាមួយគ្នានោះបង្កើនថ្លៃចំណាយនៃការបង្ក្រាបនោះ។ វិធីមួយដែលពួកគេធ្វើនោះ គឺតាមរយៈការវាយតម្លៃហានិភ័យឱ្យបានត្រឹមត្រូវ និងជម្រើសយុទ្ធវិធី ដោយសារតែមិនមែនយុទ្ធវិធីទាំងអស់ប្រឈមនឹងការបង្ក្រាបស្មើៗគ្នានោះទេ។ ខណៈដែលសកម្មភាពប្រមូលផ្តុំ ដែលមានដូចជា ការធ្វើបាតុកម្មទ្រង់ទ្រាយធំទំនងជារងការបង្ក្រាបភាគច្រើនយុទ្ធវិធីវិមជ្ឈការ ដូចជា ពហិការអតិថិជន កូដកម្មដោយការនៅផ្ទះ ការមិនទៅរៀនដោយយកលេសឈឺ ឬក៏ការបង្ហាញសញ្ញាតូចៗដោយអនាមិក នៅតាមកន្លែងសាធារណៈ គឺអាចពិបាកសម្រាប់របបមួយដើម្បីធ្វើការបង្ក្រាប។ ចំណុចនេះដោយសារតែថាការចូលរួមក្នុងយុទ្ធវិធីខ្លះ (ដូចជា ពហិការអតិថិជន) មិនបង្ហាញជាក់ច្បាស់ (អ្នកមិនអាចមើលដឹងទេថានរណាម្នាក់កំពុងតែពហិការទំនិញណាមួយឬក៏អត់នោះ) ឬក៏ដោយសារតែអ្នកប្រព្រឹត្តនៅរាយប៉ាយ និងមានលទ្ធភាពក្នុងការបដិសេធ (ដូចជា កូដកម្មដោយនៅផ្ទះតម្រូវឱ្យប៉ូលីសត្រូវតែទៅសួរដល់ផ្ទះកម្មករគ្រប់គ្នា និងអ្នកចូលរួមនៅក្នុងការមិនទៅរៀនដោយប្រើលេសឈឺអាចនិយាយថាគេពិតជាមិនស្រួលខ្លួនមែននៅថ្ងៃនោះ)។

ជំពូកនេះមាននៅក្នុង ៖ ម៉ាជីរ ប៊្រូយ និង ម៉ារៀ ជេ. ស្ទេហ្វិន, «តើអំណាចផ្តាច់ការនិយមកំពុងតែរៀបចំផែនការត្រលប់មកវិញ?» វ៉ាស៊ីងតោន ឌីស៊ី ក្រុមប្រឹក្សាអាត្លង់ទិច, ឆ្នាំ២០១៥។

ក្នុងឆ្នាំ១៩៨៣ នៅស៊ីលី ក្រុមប្រឆាំងនយោបាយតបតនឹងអំណាចផ្តាច់ការរបស់ អាហ្គុស្តូ ភីណូឆេត ត្រូវរកវិធីដើម្បីចៀសវាងពីការបង្ក្រាបរបស់ជននេះ។ មួយទស្សវត្សរ៍នៃការចាប់ខ្លួនទ្រង់ទ្រាយធំ ការប្រហារជីវិត ទណ្ឌកម្ម និងការបាត់ខ្លួន មានន័យថាមនុស្សម្នានាំគ្នាខ្លាចមិនហ៊ានរៀបចំ ឬកៀរគរគ្នាទៀតនោះទេ។ នៅខែមេសា កម្មករជីករ៉ែបានអំពាវនាវឱ្យមានការធ្វើកូដកម្មនៅក្រៅ សាន់ជាអាហ្គូ ប៉ុន្តែ ភីណូឆេត បានគំរាមថានឹងមានការបង្ហូរឈាម តាមរយៈការបញ្ជូនទាហានឱ្យទៅលោមព័ទ្ធកន្លែងជីករ៉ែនោះមុនពេលកូដកម្មចាប់ផ្តើម។ ចំពោះមុខការបង្ក្រាបបែបនោះ អ្នកដឹកនាំកម្មករបានលុបចោលការធ្វើកូដកម្ម ហើយផ្ទុយទៅវិញអំពាវនាវឱ្យមានទិវាធ្វើបាតុកម្ម ដែលមនុស្សគ្រប់គ្នាអាចធ្វើបាតុកម្មប្រឆាំងនឹងរបបតាមរយៈការធ្វើការដោយយឺតៗ ដើរយឺតៗ បើកឡានយឺតៗ ហើយរៀងរាល់ម៉ោង៨យប់ ត្រូវគោះចានគោះឆ្នាំង។[16] មានការចូលរួមយ៉ាងទូលំទូលាយ និងដែលមិនធ្លាប់មានក្នុងផ្នែកទាំងអស់នេះ ហើយចំណុចនេះបាននាំឱ្យមានការអំពាវនាវឱ្យមានការធ្វើបាតុកម្មរៀងរាល់ខែ។ ការធ្វើបែបនេះ ជាជំហានដំបូងដ៏ធំបំផុត ក្នុងការបំបែកស្រទាប់នៃភាពភ័យខ្លាច និងការបែកខ្ញែកដែលជាសសរស្តម្ភនៃការគ្រប់គ្រងរបស់ភីណូឆេត។ សកម្មភាពទាំងនេះ មានកម្រិតទទួលយកហានិភ័យតិចតួចសម្រាប់អ្នកចូលរួម និងក៏មិនអាចបង្ក្រាបបានដោយកងកម្លាំងសន្តិសុខរបស់ភីណូឆេត ពុំមានចម្លើយចំពោះយុទ្ធវិធីដែលវិមជ្ឈការក្នុងទ្រង់ទ្រាយធំបែបនោះទេ។

ផ្នែកមួយទៀតនៃការកាត់បន្ថយផលជះនៃការបង្ក្រាប ឬក៏បង្កើននូវថ្លៃចំណាយនៃការបង្ក្រាប និងលទ្ធភាពដែលធ្វើឱ្យការបង្ក្រាបនេះជះផលអវិជ្ជមានបកមកវិញ រួមចំណែកពីការបញ្ជាក់ឱ្យច្បាស់នូវទុក្ខកង្វល់ជាក់លាក់មួយចំនួនក្នុងន័យសម្រាប់អ្នកដែលមិនចូលចិត្តនយោបាយ (បាតុកម្មទាមទារឱ្យមានទឹកស្អាត និងភូមិឋានដែលមានសុវត្ថិភាព ផ្ទុយនឹងការទាមទារឱ្យផ្តួលរំលំរបបមួយ) ការកសាងបន្ទាត់ច្បាស់លាស់នៃការបន្តវេនរបស់អ្នកដឹកនាំ និងការភ្ជាប់គម្លាតសង្គមរវាងអ្នកចូលរួមចលនា និងក្រុមក្នុងស្រុក និងក្រុមក្រៅស្រុក ដើម្បីឱ្យការបង្ក្រាបលើចលនានឹងកាន់តែជះផលអវិជ្ជមានបកមកវិញ។ ឧទាហរណ៍ នៅពេលដែលអ្នកសរសេរប្លុកជនជាតិអេហ្ស៊ីប ខាលេត សៃត ត្រូវបានអូសចេញពីហាងកាហ្វេនៅឆ្នាំ២០១០ និងត្រូវបានវាយរហូតដល់ស្លាប់ដោយក្រុមកងកម្លាំងសន្តិសុខ ព្រោះតែបានលាតត្រដាងអំពើពុករលួយ ពេលនោះក្រុមហ្វេសប៊ុករបស់អ្នកប្រឆាំង មានឈ្មោះថា «យើងគឺ ខាលេត សៃត» តបតនឹងការប៉ុនប៉ងរបស់រដ្ឋាភិបាលអេហ្ស៊ីបក្នុងការបន្ទាបតម្លៃជីវិតរបស់សៃត។ តាមរយៈវត្តមានរបស់ពួកគេ ពួកគេបានបញ្ជាក់ច្បាស់ថា សៃត មានចំណុចរួមគ្នាជាច្រើនទៅនឹងជនជាតិអេហ្ស៊ីបសាមញ្ញ ដូច្នេះ ធ្វើឱ្យការបង្ក្រាបនោះជះផលអវិជ្ជមានបកមកវិញ។

[16] «កម្លាំងមួយដែលកាន់តែមានអំណាច» ដឹកនាំដោយ ស្ទីវ យ៉ក។ យ៉ក ហ្ស៊ីម៉ីមែន ឆ្នាំ២០០០ ភាពយន្ត។

**ជំពូកនេះមាននៅក្នុង ៖ ម៉ាជីវ ប៊្លូយ និង ម៉ារៀ ជេ. ស្ទេហ្វិន, «តើអំណាចផ្តាច់ការនិយមកំពុងតែរៀបចំផែនការត្រលប់មកវិញ?» វ៉ាស៊ីងតោន ឌីស៊ី ក្រុមប្រឹក្សាអាត្លង់ទិច, ឆ្នាំ២០១៥។**

## ៦. បង្កើនការចុះចូលពីចលនានៃគូបដិបក្ខ

ខណៈពេលដែលការតស៊ូដោយពលរដ្ឋដំណើរការទៅមុខ ការតស៊ូនេះតែងតែធ្វើឱ្យមានការបង្វែរនូវភក្តីភាព និងការចុះចូលពីអ្នកគាំទ្រសកម្ម និងអសកម្មនៃគូបដិបក្ខ។ ឧទាហរណ៍ អ្នកកំណែទម្រង់ និងជនក្បាលរឹងក្នុងរដ្ឋាភិបាលអាចនឹងតស៊ូគ្នាទៅវិញទៅមកជាសាធារណៈ ដើម្បីដណ្ដើមអំណាចគ្រប់គ្រង។ ផលប្រយោជន៍ផ្នែកសេដ្ឋកិច្ចអាចនឹងដាក់សម្ពាធដល់រដ្ឋឱ្យឆ្លើយតបនឹងតម្រូវការរបស់ចលនា ដើម្បីឱ្យអាជីវកម្មបើកឡើងវិញជាធម្មតា។ អ្នកគាំទ្ររបបដូចជា ទាហាន ប៉ូលីស ការិយាធិបតេយ្យ និងអ្នកដទៃទៀតក៏អាចនឹងចាប់ផ្ដើមបង្វែរភក្តីភាព ប្រហែលជាដោយសារតែពួកគេត្រូវបានបញ្ចុះបញ្ចូលដោយយល់ស្របជាមួយនឹងតម្រូវការរបស់ចលនា ខ្ពើមរអើមនឹងរបបនេះ ឬដោយសារតែពួកគេមានសមាជិកក្រុមគ្រួសារ និងមិត្តភក្តិដែលចូលរួមក្នុងការតស៊ូដោយពលរដ្ឋ។ ទោះបីជាឥស្សរជនដែលគាំទ្រដល់របបនេះ ក៏អាចចាប់ផ្ដើមសង្ស័យពីស្ថិរភាពរបស់របបនេះ និងក្លាយទៅជាអព្យាក្រឹត ដើម្បីកុំឱ្យខ្លួនត្រូវជ្រើសយកក្រុមខុសក្នុងប្រវត្តិសាស្ត្រ ប្រសិនបើការតស៊ូដោយពលរដ្ឋបានជោគជ័យនោះ។

ក្នុងបដិវត្តន៍ទឹកក្រូចរបស់អ៊ុយក្រែន ក្នុងឆ្នាំ២០០៤ ក្រុមប្រឆាំងស្វែងរកទំនាក់ទំនងជាមួយនឹងកងកម្លាំងសន្តិសុខដោយតាំងចិត្ត ដោយពឹងផ្អែកលើមន្ត្រីយោធាដែលចូលនិវត្តន៍ជាអន្តរការី។[17] ពីពេលមួយទៅពេលមួយ ក្រុមប្រឆាំងបានបង្ហាញតាមរយៈសកម្មភាពរបស់ពួកគេថា ពួកគេគឺអហិង្សា និងមានហេតុផលអំពាវនាវឱ្យកងកម្លាំងសន្តិសុខបម្រើ និងការពារប្រយោជន៍សាធារណៈ ភ្ជាប់ទំនាក់ទំនងសង្គមតាមរយៈភាតរភាព ពាក្យស្លោក និងសកម្មភាព (ដូចជាការឱ្យផ្កាកុលាបទៅកាន់ប៉ូលីសបង្ក្រាបកុប្បកម្ម) លាតត្រដាងអំពើពុករលួយនៃរបបដែលកំពុងកាន់អំណាច និងជាចុងក្រោយបង្កឱ្យមានការបង្វែរភក្តីភាពក្នុងចំណោមកម្លាំងសន្តិសុខ។ ខណៈពេលត្រូវចូលរួមក្នុងការបង្ក្រាប មានទាហាន និងប៉ូលីសអ៊ុយក្រែនជាច្រើន បានក្លាយទៅជាអព្យាក្រឹត។ ករណីស្រដៀងគ្នាបែបនេះក៏កើតមាននៅស៊ែប៊ី ក្រោមការដឹកនាំរបស់មីឡូសូវិកដែរ។ ដោយពុំបានចុះចូលដោយបើកចំហរ កងម្លាំងសន្តិសុខគ្រាន់តែបញ្ឈប់ការអនុវត្តតាមបញ្ជារបស់របបនេះ។ នៅថ្ងៃដល់ចំណុចកំពូលរបស់ ចលនា អដប៉ ថ្ងៃទី៥ ខែតុលា មន្ត្រីប៉ូលីសដែលទទួលខុសត្រូវក្នុងការទម្លាក់សារធាតុគីមីចេញពីឧទ្ធម្ភាគចក្រដើម្បីបំបែកហ្វូងមនុស្សនៅ បេលក្រាដ បដិសេធក្នុងការទម្លាក់ ដោយអះអាងថាគាត់មិនអាចមើលឃើញហ្វូងមនុស្សច្បាស់ ដោយសារតែបញ្ហាអាកាសធាតុ ទោះបីជាពេលនោះអាកាសធាតុស្រលះល្អក៏ដោយ។ មន្ត្រីប៉ូលីសនេះក្រោយមកបានលើកឡើងថា លោក

[17] ប៊ីននេឌីក អេនីកា ឡូក និង អ៊ីវ៉ាន ម៉ារ៉ូវិក ឆ្នាំ២០០៦។ «អំណាច និងការបញ្ចុះបញ្ចូល ៖ យុទ្ធសាស្ត្រអហិង្សាក្នុងការជះឥទ្ធិពលដល់កងកម្លាំងសន្តិសុខរបស់រដ្ឋនៅស៊ែប៊ី (២០០០) និងអ៊ុយក្រែន (២០០៤)»។ ការសិក្សារបបកុំម្មុយនីស្ត និងរបបបន្ទាប់ពីកុំម្មុយនីស្ត ៣៩, លេខ ៣ (ខែកញ្ញា) ទំព័រ ៤១១ ដល់ ៤២៩។

**ជំពូកនេះមាននៅក្នុង ៖ ម៉ាជីរ ប៊្លូយ និង ម៉ារៀ ជេ. ស្ទេហ្វិន, «តើអំណាចផ្ដាច់ការនិយមកំពុងតែរៀបចំផែនការត្រលប់មកវិញ?» វ៉ាស៊ីងតោន ឌីស៊ី ក្រុមប្រឹក្សាអាត្លង់ទិច, ឆ្នាំ២០១៥។**

មានអារម្មណ៍ថាលោកមិនអាចអនុវត្តតាមបញ្ជានេះបានទេ ដោយសារតែសមាជិកក្រុមគ្រួសាររបស់លោកក៏អាចនៅក្នុងចំណោមក្រុមបាតុករនៅថ្ងៃនោះដែរ។[18]

មិនថាត្រូវបានដឹកនាំដោយការបញ្ចុះបញ្ចូល ឬក៏ប្រយោជន៍ផ្ទាល់ខ្លួន ការចុះចូលទាំងអស់នេះ តែងតែជាលទ្ធផលនៃដំណើរការរយៈពេលយូរ ដែលបង្កឡើងដោយចលនាតស៊ូដោយពលរដ្ឋ។ ស្រដៀងគ្នាទៅនឹងនិន្នាការពីរទៀតនៅក្នុងបញ្ជីចំណុចដែលត្រូវធ្វើ និន្នាការនេះបានលេចឡើងចេញពីការចូលរួមរបស់ចលនាមួយដោយមានសាមគ្គីភាព ការធ្វើផែនការ និងវិន័យអហិង្សា។ ទិន្នន័យបានបង្ហាញថាការចូលរួមក្នុងកម្រិតខ្ពស់របស់អ្នកចូលរួមចម្រុះគ្នា មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងការបង្កើនឱកាសនៃការចុះចូល ហើយសាមគ្គីភាព ការធ្វើផែនការ និងវិន័យអហិង្សា សុទ្ធតែរួមចំណែកទៅក្នុងការចូលរួមយ៉ាងទូលំទូលាយ និងចម្រុះនេះដែរ។ ជាពិសេស វិន័យអហិង្សាគឺមានសារៈសំខាន់ដើម្បីបង្កើតឱ្យមានការចុះចូល។ ដូច្នេះ ដរាបណាដែលចលនានៅតែរក្សាភាពអហិង្សា និងចៀសវាងការធ្វើអន្តរកាលទៅរកការបះបោរដោយហិង្សា (ដូចករណីដ៏អាណោចអាធម៌របស់ប្រទេសស៊ីរៀ ក្នុងឆ្នាំ២០១១) នោះចលនាអាចបន្តតស៊ូបានមួយថ្ងៃទៀត និងបើកចំហលទ្ធភាពសម្រាប់ការចុះចូល។ ប្រសិនបើគោលដៅនៃការបង្វែរភក្តីភាពនៅក្នុងរបបមិនរងការគំរាមកំហែងដោយការបះបោរហិង្សា សក្តានុពលក្នុងការចុះចូលរបស់ពួកគេនៅបន្ត ជាការគំរាមកំហែងចំពោះភាពស្អិតរមួតនៃរចនាសម្ព័ន្ធអំណាចរបស់របបផ្តាច់ការ។

## ផលប៉ះពាល់សម្រាប់តួអង្គខាងក្រៅ

បញ្ជីចំណុចដែលត្រូវធ្វើនេះ មិនមែនគ្រាន់តែជាមគ្គុទេសក៍ដ៏មានប្រយោជន៍សម្រាប់ក្រុមអ្នកប្រឆាំងនោះទេ។ ក្រុមដទៃទៀត ក៏អាចអនុវត្តតាមបញ្ជីនេះផងដែរ ដើម្បីបង្កើនការអនុវត្តរបស់ពួកគេពាក់ព័ន្ធនឹងជម្លោះទាំងនេះ។

ឧទាហរណ៍ បញ្ជីនេះអាចជួយឱ្យអ្នកកាសែតរាយការណ៍ដោយភាពឆ្លាតវៃជាងមុន ស្តីអំពីការតស៊ូដោយពលរដ្ឋ។ ប្រសិនបើអ្នកកាសែតមានបំណងចង់យល់ដឹងកាន់តែទូលំទូលាយអំពីជម្លោះមួយ បញ្ជី នេះអាចបញ្ជាក់បានថា ការឱ្យអ្នកកាសែតម្នាក់នៅពីមុខគោលដៅដែលកំពុងតែឆេះដោយសារតែគ្រាប់បែកដបសាំង នៅទីក្រុងគៀវ នៅដើមឆ្នាំ២០១៤ ដើម្បីឱ្យអ្នកកាសែតនោះអាចប៉ាន់ស្មានថាតើអំពើហិង្សាអាចនឹងកាន់តែអាក្រក់ទៅ មិនបានបញ្ជាក់ពីកម្លាំងជំរុញនៅក្នុងជម្លោះនោះទេ។ ប៉ុន្តែការស៊ើបអង្កេតក្នុងស្ថានភាពនៃ សាមគ្គីភាព និងការធ្វើផែនការរបស់ចលនា ប្រភពនៃការបាត់បង់វិន័យអហិង្សា ការបង្កើនការចូលរួម

[18] បទសម្ភាសន៍ជាមួយនឹង នេបូស្ហា កូវិក, វេសេនជេ ណូវ៉ូស្ទី ថ្ងៃទី២ ខែតុលា ឆ្នាំ២០១០។

**ជំពូកនេះមាននៅក្នុង ៖ ម៉ាធីវ ប៊ូរ៉ូយ និង ម៉ារៀ ជេ. ស្ទេហ្វិន, «តើអំណាចផ្តាច់ការនិយមកំពុងតែរៀបចំផែនការត្រលប់មកវិញ?» វ៉ាស៊ីងតោន ឌីស៊ី ក្រុមប្រឹក្សាអាត្លង់ទិច, ឆ្នាំ២០១៥។**

របស់ប្រជាពលរដ្ឋជម្មតា ការកាត់បន្ថយនូវផលជះនៃការបង្រ្កាបមកលើចលនាមួយ និងថាតើកងកម្លាំងសន្តិសុខពិតជាគោរពតាមបញ្ជាទាំងស្រុងឬអត់ កុំនិយាយពីការចុះចូល អាចនឹងផ្តល់នូវការវិភាគបានដោយមិនធ្លាប់មានពីមុន។ បន្ថែមពីលើនេះ គឺជាការយល់ពីការបាត់បង់ការគាំទ្រក្នុងសហគមន៍អាជីវកម្ម ហើយវាកាន់តែច្បាស់ថាហេតុអ្វីបានជា ប្រធានាធិបតី អ៊ុយក្រែន យ៉ាណុកូវិច បានគេចខ្លួននៅខែកុម្ភៈឆ្នាំនេះ រយៈពេលប៉ុន្មានម៉ោងក្រោយបន្ទាប់ពីអំពើហិង្សាដ៏អាក្រក់ឃោរឃៅបំផុតដែលប្រព្រឹត្តដោយរបបនេះ ជះផលអវិជ្ជមានបកមកវិញ។ ការអភិវឌ្ឍន៍ទាំងអស់នេះ អាចនឹងទស្សន៍ទាយដឹងមុនប្រសិនបើមនុស្សម្នាក់កំពុងតែមើលចំសូចនាករដ៏ត្រឹមត្រូវមួយទុកជាមុន។

ប្រសិនបើត្រូវបានពិចារណាដោយអ្នករៀបចំគោលនយោបាយ ក្នុងពាក់កណ្តាលឆ្នាំចុងក្រោយនៃឆ្នាំ ២០១១ បញ្ជីនៃចំណុចដែលត្រូវធ្វើនេះ អាចនឹងបញ្ជាក់ពីឱកាសដ៏សម្បើមសម្រាប់ការតស៊ូដោយពលរដ្ឋដែលមានជ័យជំនះប្រឆាំងនឹងរបបអាសាដ នៅស៊ីរៀ។ ការបន្តការបង្វែរភក្តីភាព (លើសពីទាហាន សាន់នី) នៅក្នុងក្រុមយោធាលើសពីរបប អាចនឹងត្រូវបានមើលឃើញថាជាក្តីសង្ឃឹមដ៏ល្អបំផុតសម្រាប់ភាពជោគជ័យ។ ការដកការគាំទ្រដោយសមាជិកនៃសហគមន៍អាជីវកម្ម គឺជាសូចនាករមួយទៀត។ ក្នុងករណីនេះ ការជំរុញនៃ ទាហានរំដោះស៊ីរៀ នៅក្នុងដើមឆ្នាំ២០១២ ដើម្បីវាយតបតនឹងយោធាអាឡាវីត របស់របបអាសាដដែលនៅសេសសល់ គួរតែអាចត្រូវបានឃើញថាជាការគ្មានបានការ ឬមិនដូច្នោះទេ ជាប្រផ្នូលនៃសោកនាដកម្មមួយ។

បញ្ជីចំណុចដែលត្រូវធ្វើនេះ ក៏អាចមានប្រយោជន៍ជាពិសេសក្នុងការបង្កើតបទដ្ឋាន គ្រប់គ្រងជំនួយពីខាងក្រៅសម្រាប់ចលនាអំណាចជនជាតិដើមភាគតិច។ ឧទាហរណ៍ សមត្ថភាពបីដំបូងនៅលើបញ្ជីចំណុចដែលត្រូវធ្វើ គឺផ្អែកលើជំនាញ និងអាចបង្ហាញតាមរយៈការធ្វើឱ្យកាន់តែល្អប្រសើរឡើងដោយ ការផ្លាស់ប្តូរព័ត៌មានយ៉ាងសកម្ម។ ក្នុងមាត្រា១៩ នៃសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស ជនផ្តាច់ការមិនអាចរឹតត្បិតលំហូរនៃព័ត៌មានត្រឹមតែក្នុងព្រំដែនរបស់ខ្លួន ឬដាក់ទណ្ឌកម្មពលរដ្ឋដែលចែកចាយបន្តនូវព័ត៌មាននោះទៅកាន់ក្រុមប្រឆាំងនោះទេ។ ចំណុចទាំង៦ ដែលនៅលើបញ្ជីចំណុចដែលត្រូវធ្វើនេះអាចពញ្ញាក់ស្មារតីអំពីផ្លូវសម្រាប់ឱ្យមានការច្នៃប្រឌិតផ្នែកបច្ចេកវិទ្យា ដែលអាចសម្របសម្រួលការសាបព្រោះនូវសមត្ថភាពទាំងបី និងនិន្នាការទាំងបី។

## បញ្ជីចំណុចដែលត្រូវធ្វើ និងជម្លោះដែលនឹងជះឥទ្ធិពលដល់អនាគតរបស់យើង

ជំពូកនេះមាននៅក្នុង ៖ ម៉ាធីវ ប៊ូរ៉ូយ និង ម៉ារៀ ជេ. ស្ទេហ្វិន, «តើអំណាចផ្តាច់ការនិយមកំពុងតែរៀបចំផែនការត្រលប់មកវិញ?» វ៉ាស៊ីងតោន ឌីស៊ី ក្រុមប្រឹក្សាអាត្លង់ទិច, ឆ្នាំ២០១៥។

មជ្ឈដ្ឋាននៃជម្លោះអហិង្សា ដែលត្រូវបានតតាំង គឺមានភាពស្មុគស្មាញណាស់ ហើយពលរដ្ឋអ្នកតស៊ូ តម្រូវឱ្យមានការសម្របសម្រួលថ្នាក់មូលដ្ឋាន ដើម្បីចាត់លំដាប់លំដោយនៃយុទ្ធវិធីទៅក្នុងយុទ្ធសាស្ត្រសម្រាប់យកជ័យជំនះ ហើយជាញឹកញាប់តែងតែប្រឈមនឹងការវង្វេងស្មារតី។ ភាពភ័យខ្លាចជាធម្មជាតិរបស់ពួកគេ ក្នុងការធ្វើសេចក្តីសម្រេចចិត្តខុស ដោយប្រើជីវិត និងសេរីភាពរបស់ប្រជាពលរដ្ឋជាទុនអាចនឹងបង្កើតឱ្យមានភាពស្ទាក់ស្ទើរដែលជនផ្តាច់ការចង់ឃើញ ហើយក៏នឹងជំរុញឱ្យមានការភ័ន្តច្រលំពីភាពមិនងាយរងគ្រោះរបស់ជនផ្តាច់ការ។

បញ្ជីចំណុចដែលត្រូវធ្វើនេះ អាចជួយឱ្យក្រុមប្រឆាំងមើលឃើញកាន់តែច្បាស់ពីអារម្មណ៍វង្វេងស្មារតីនេះ និងត្រួសត្រាយផ្លូវទៅខាងមុខ។ អ្នកខ្លះអាចអះអាងថា ដោយសារតែមានអញ្ញត្តិជាច្រើនដែលជះឥទ្ធិពលបញ្ជីចំណុចដែលត្រូវធ្វើដើម្បីបញ្ចប់អំណាចផ្តាច់ការ ហាក់ដូចជាសាមញ្ញពេក ហើយការវាយតម្លៃសេចក្តីសម្រេចចិត្តដែលសំខាន់ក្នុងអំឡុងជម្លោះនាពេលខាងមុខ នឹងតម្រូវឱ្យមានការយកចិត្តទុកដាក់ជាខ្លាំងលើកត្តាផ្សេងៗដែលប្លែកពីគេក្នុងពេលវេលា និងទីកន្លែងណាមួយនោះ។

ទោះបីជាយ៉ាងនេះក៏ដោយ បញ្ជីចំណុចដែលត្រូវធ្វើនេះ នឹងមិនអំពាវនាវឱ្យមានការព្រងើយកន្តើយចំពោះកត្តាជាក់លាក់ក្នុងស្ថានភាពនីមួយៗនោះទេ ប៉ុន្តែគឺចង់ឱ្យមានការយល់ពីកត្តាទាំងនោះក្នុងបរិបទនៃក្របខណ្ឌយុទ្ធសាស្ត្រដែលទូលាយជាងមុន ដែលបង្ហាញអំពីរបៀប និងមូលហេតុដែលការតស៊ូដោយពលរដ្ឋអាចយកឈ្នះបាន។ អាធុល ហ្គាវ៉ាន់ដេ ដែលបានស្រាវជ្រាវពីសារៈសំខាន់នៃបញ្ជីចំណុចដែលត្រូវធ្វើ ក្នុងបរិបទផ្សេងៗគ្នាជាច្រើន បានសរសេរថា៖

> បញ្ជីចំណុចដែលត្រូវធ្វើហាក់ដូចជាអាចការពារនរណាក៏បាន ថ្វីបើធ្លាប់មានបទពិសោធន៍ ពីបរាជ័យក្នុងការងារជាច្រើនជាងអ្វីដែលយើងបានដឹងទៅទៀត។ ពួកគេផ្តល់នូវសំណាញ់នៃការយល់ដឹង។ ពួកគេអាចចាប់នូវគុណវិបត្តិផ្លូវចិត្តដែលមានក្នុងចិត្តរបស់យើងទាំងអស់គ្នា គុណវិបត្តិនៃការចងចាំ និងការយកចិត្តទុកដាក់ និងភាពម៉ត់ចត់...[19]
>
> ក្រោមលក្ខខណ្ឌនៃភាពស្មុគស្មាញដ៏ពិតប្រាកដ ខណៈដែលចំណេះដឹងតម្រូវឲ្យមានលើសពី អ្វីដែលបុគ្គលម្នាក់ និងដែលការគ្រប់គ្រងមិនអាចទស្សន្ទទាយមុនបាន... [បញ្ជីចំណុចដែលត្រូវធ្វើដែលមានប្រសិទ្ធភាព] ជានាថាអ្វីដែលមើលទៅធ្លួតៗ ប៉ុន្តែចាំបាច់នឹងមិនត្រូវបានមើលរំលង និង

[19] ហ្គាវ៉ានដេ អាធុល ឆ្នាំ២០០៩ «សេចក្តីថ្លែងនៃបញ្ជីចំណុចដែលត្រូវធ្វើ ៖ របៀបដែលធ្វើឱ្យអ្វីៗត្រឹមត្រូវ» ញូវយ៉ក ភីកាដូ ទំព័រទី៤៧។

**ជំពូកនេះមាននៅក្នុង ៖ ម៉ាជីរ ប៊្លូយ និង ម៉ារៀ ជេ. ស្ទេហ្វិន, «តើអំណាចផ្តាច់ការនិយមកំពុងតែរៀបចំផែនការត្រលប់មកវិញ?» វ៉ាស៊ីងតោន ឌីស៊ី ក្រុមប្រឹក្សាអាត្លង់ទិច, ឆ្នាំ២០១៥។**

... ជានាថាមនុស្សនាំគ្នាជជែក និងសម្របសម្រួល... ដើម្បីគ្រប់គ្រងនូវភាពខុសប្លែកគ្នា និងភាពដែលមិនអាចទាយទុកមុនឱ្យបានល្អប្រសើរបំផុតតាមដែលគេអាចដឹង។[20]

បញ្ជីចំណុចដែលត្រូវធ្វើ អាចនឹងមិនមែនជាសូចនាករចុងក្រោយ ក្នុងការកំណត់ថាតើនរណាម្នាក់នឹងឈ្នះ ៖ ជនផ្តាច់ការ ឬក៏ពលរដ្ឋអ្នកតស៊ូ។ ប៉ុន្តែ បញ្ជីនេះអាចដើរតួជាបណ្តុំនៃសូចនាករដែលចាំបាច់ និងជាបន្តបន្ទាប់ ក្នុងការយល់ពីរបៀបដែលពលរដ្ឋទាមទារសេរីភាព អាចយកឈ្នះនូវប្រព័ន្ធអំណាចផ្តាច់ការដែលចាក់ឫស។

[20] ដូចខាងលើ ទំព័រទី៧៩។

ជំពូកនេះមាននៅក្នុង ៖ ម៉ាជីវ ប៊្លូយ និង ម៉ារៀ ជេ. ស្ទេហ្វិន, «តើអំណាចផ្តាច់ការនិយមកំពុងតែរៀបចំផែនការត្រលប់មកវិញ?» វ៉ាស៊ីងតោន ឌីស៊ី ក្រុមប្រឹក្សាអាត្លង់ទិច, ឆ្នាំ២០១៥។